# សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល

## ការវិភាគចុងក្រោយលើសេចក្តីព្រាងច្បាប់លើកទីពីរ

---

របាយការណ៍សង្ខេប លីកាដូ

ខែមីនា ឆ្នាំ២០១១


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

LICADHO

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

## សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស លីកាដូ

លីកាដូ គឺជាអង្គការសិទ្ធិមនុស្សជាតិមួយនៅកម្ពុជា។ ចាប់តាំងពីអង្គការលីកាដូត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩២ អង្គការនេះ គឺជាអង្គការស្ថិតនៅជួរមុខគេក្នុងកិច្ចការពារសិទ្ធិមនុស្សនៅកម្ពុជា និងលើកស្ទួយការគោរពសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយតាមរយៈរាជរដ្ឋាភិបាលកម្ពុជា និងស្ថាប័ននានា។ ការកសាងសមិទ្ធិផលរបស់ខ្លួនក្នុងអតីតកាល **លីកាដូ** បានបន្តដើរតួជាអ្នកតស៊ូមតិ សម្រាប់ប្រជាពលរដ្ឋ និងឃ្លាំមើលរដ្ឋាភិបាលតាមរយៈ កម្មវិធីសិទ្ធិមនុស្សនានាពីការិយាល័យកណ្តាលរបស់ខ្លួននៅភ្នំពេញ និងនៅតាមសាខា ទូទាំង១២ ខេត្ត-ក្រុងផ្សេងទៀត។

**អង្គការលីកាដូអនុវត្តសកម្មភាពរបស់ខ្លួនតាមរយៈកម្មវិធីធំៗពីរៈ**
**កម្មវិធីឃ្លាំមើល និងការពារសិទ្ធិមនុស្សៈ**

- **ឃ្លាំមើលការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយបុគ្គលរបស់រដ្ឋលើការរំលោភសិទ្ធិស្ត្រីនិងងការរំលោភសិទ្ធិកុមារៈ**បុគ្គលិកធ្វើការស៊ើបអង្កេតលើករណីរំលោភសិទ្ធិមនុស្ស ដែលប្រព្រឹត្តដោយបុគ្គល របស់រដ្ឋ ចំពោះការរំលោភបំពានលើស្ត្រី និងកុមារ ហើយជនរងគ្រោះត្រូវបានផ្តល់ សេវាជួយជ្រោមជ្រែងតាមរយៈ ការធ្វើអន្តរាគមន៍ជាមួយអាជ្ញាធរមូលដ្ឋាន។
- **ការប្រឹក្សាផ្នែកច្បាប់និងកិច្ចការពារផ្នែកច្បាប់ៈ**ជនរងគ្រោះត្រូវបានផ្តល់ជូននូវការប្រឹក្សាផ្នែកច្បាប់ ហើយចំពោះករណីសំខាន់ៗទទួលបាននូវកិច្ចការពារផ្នែកច្បាប់ដែលផ្តល់ជូនដោយក្រុមប្រឹក្សាផ្នែកច្បាប់ និងក្រុមមេធាវីការពារសិទ្ធិមនុស្ស។
- **ការឃ្លាំមើលពន្ធនាគារៈ** អ្នកស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារចំនួន១៨ ដើម្បីធ្វើការវាយតម្លៃ អំពីស្ថានភាពនៅក្នុងពន្ធនាគារ និងដើម្បីធានាថាពិរុទ្ធជនទទួលបាននូវតំណាងផ្នែកច្បាប់។
- **ជំនួយផ្នែកវេជ្ជសាស្ត្រៈ** ក្រុមគ្រូពេទ្យផ្តល់សេវាវេជ្ជសាស្ត្រដល់អ្នកទោស និងមន្ត្រីពន្ធនាគារចំនួន១២កន្លែង។ បន្ថែមពីលើនេះ ក៏ជួយផ្តល់សេវាវេជ្ជសាស្ត្រ និងបញ្ជូនជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ទៅកាន់មន្ទីរពេទ្យ។
- **សវាកម្មសង្គមកិច្ចៈ** ក្រុមការងារធ្វើការវាយតម្លៃពីតម្រូវការរបស់ជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេ ហើយផ្តល់ជំនួយជាសម្ភារៈ និងម្ហូបអាហាររយៈពេលខ្លី។

**កម្មវិធីទំនាក់ទំនង និងការទាក់ទាញមតិគាំទ្រ:**

- **ការហ្វឹកហ្វឺនសហគមន៍ អប់រំ និងការតស៊ូមតិ:** អ្នកហ្វឹកហ្វឺន និងអ្នកតស៊ូមតិធ្វើការអប់រំដល់សាធារណជន អំពីសិទ្ធិស្ត្រី និងសិទ្ធិកុមារបង្កើតបណ្តាញការពារនៅតាមមូលដ្ឋាន និងធ្វើការតស៊ូមតិដើម្បីឲ្យមានការផ្លាស់ប្តូរសង្គម និងច្បាប់។
- **ការតស៊ូមតិជាសាធារណៈ និងតាមសហគមន៍:** ករណីរំលោភសិទ្ធិមនុស្សដែលស៊ើបអង្កេតដោយ លីកាដូត្រូវបានចងក្រងទុកនៅក្នុងប្រព័ន្ធទិន្នន័យដើម្បីឲ្យមានភាពងាយស្រួលក្នុងការស្វែងរកព័ត៌មាន វិភាគ ផលិតជារបាយការណ៍ជាប្រចាំ(ការបោះពុម្ពជារបាយការណ៍ និងរបាយការណ៍សោតទស្សន៍)។

**ចំពោះព័ត៌មានបន្ថែមសូមទាក់ទង**


លោកស្រីវេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ

អាសយដ្ឋាន: អង្គការលីកាដូ (សម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធិមនុស្ស)

ផ្ទះលេខ ១៦ ផ្លូវលេខ ៩៩ រាជធានីភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (+៨៥៥) ២៣ ៧២៧ ១០២/៣៦៤ ៩០១ ទូរសារ: (+៨៥៥) ២៣ ៧២៧ ១០២/២១៧ ៦២៦

អ៊ីម៉ែល: contact@licadho-cambodia.org

គេហទំព័រ: http://www.licadho-cambodia.org/

# មាតិកា

១- សេចក្តីផ្តើម ........................................................................១

២- និដ្ឋភាពទូទៅ ...................................................................... ២

៣- បញ្ហាចម្បងៗរបស់សេចក្តីព្រាងច្បាប់ ......................................... ៧

៤- បទដ្ឋានអន្តរជាតិ ..................................................................១៧

៥- សេចក្តីសន្និដ្ឋាន និងអនុសាសន៍ចុងក្រោយ ................................១៨

អនុសាសន៍.............................................................................. ១៩

# ១- សេចក្តីផ្តើម

នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០ រាជរដ្ឋាភិបាលកម្ពុជាបានចេញផ្សព្វផ្សាយនូវសេចក្តីព្រាងច្បាប់ទីមួយស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។ នៅក្នុងរបាយការណ៍ដែលបានចេញផ្សាយកាលពីខែធ្នូ ឆ្នាំ២០១០[១] អង្គការលីកាដូ បានធ្វើការវិភាគទៅលើសេចក្តីព្រាងច្បាប់នោះ ព្រមទាំងបានធ្វើសេចក្តីសន្និដ្ឋានថា គោលបំណងនៃច្បាប់នេះ គឺដើម្បីត្រួតត្រា និងគាបសង្កត់ ជាជាងលើកកម្ពស់ និងពង្រឹងអង្គការសង្គមស៊ីវិលនៅកម្ពុជា។ លីកាដូ បានសន្និដ្ឋានថា សេចក្តីព្រាងច្បាប់លើកទី១ ស្ថិតនៅឆ្ងាយពីកំរិតកំណត់នៃបទដ្ឋានអន្តរជាតិសម្រាប់ច្បាប់ ស្តីពីវិស័យមិនទទួលផលកំរៃ ហើយ គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលច្រើនឆ្នាំ។

អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិលជាច្រើនបានសម្តែងនូវការព្រួយបារម្ភស្រដៀងគ្នានេះដែរ ដោយបានកត់សម្គាល់ថាច្បាប់នេះនឹងកាត់បន្ថយយ៉ាងខ្លាំងដល់លំហលទ្ធិប្រជាធិបតេយ្យនៅប្រទេសកម្ពុជា[២]។

អ្នកនាំពាក្យរបស់ក្រសួងការបរទេស សហរដ្ឋអាមេរិកមួយរូប បានអះអាងក្នុងខែមករា ឆ្នាំ២០១១ ថា "សហរដ្ឋអាមេរិកមានការព្រួយបារម្ភយ៉ាងខ្លាំង អំពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដូចដែលត្រូវបានព្រាងឡើងនេះ ហើយនឹងធ្វើការជំទាស់យ៉ាងម៉ឺងម៉ាត់ចំពោះការអនុម័តច្បាប់ណា ដែលដាក់កំហិតដល់សកម្មភាពស្របច្បាប់របស់អង្គការមិនមែនរដ្ឋាភិបាល។ ប៉ុន្មានសប្តាហ៍ក្រោយមកទៀត មានដំណើរទស្សនៈកិច្ចនៃឧបការី ក្រសួងការបរទេសសហរដ្ឋអាមេរិក លោក ខេនញ៉ែល ប៉ែរ ដែលលោកបានអះអាងថា រដ្ឋាភិបាលសហរដ្ឋអាមេរិក "បានបញ្ជាក់យ៉ាងច្បាស់ហើយថា យើងមានការព្រួយបារម្ភអំពីច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល... [និង] នៅមិនទាន់យល់នៅឡើយ ពីការចាំបាច់នៃការមានច្បាប់នេះ[៣]។ ច្បាប់ ដែលកំពុងតែមាន នាពេលបច្ចុប្បន្ននេះ មានបទបញ្ញត្តិ គ្រប់គ្រាន់សម្រាប់ផ្នែកសង្គមស៊ីវិល អស់រយៈពេលជិត ២០ឆ្នាំ មកហើយ។

ក្រោយពីមានការទាមទារយ៉ាងខ្លាំងក្លា និងមាន "ការពិគ្រោះយោបល់" មួយចំនួនជា

មួយនឹងអង្គការមិនមែនរដ្ឋាភិបាល និងក្រុមអង្គការសង្គមស៊ីវិល ក្រសួងមហាផ្ទៃ[៤]បានចេញផ្សាយនូវសេចក្តីព្រាងច្បាប់លើកទីពីរ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១១។

ក្រសួងមហាផ្ទៃបានអះអាងថា សេចក្តីព្រាងច្បាប់លើកទីពីរនេះឆ្លុះបញ្ចាំងពីកង្វល់នានារបស់សង្គមស៊ីវិលដែលបានលើកឡើង បន្ទាប់ពីការចេញផ្សព្វផ្សាយនូវសេចក្តីព្រាងលើកទីមួយកាល ពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០។ ប៉ុន្តែ ការកែប្រែសំខាន់ៗ មានតិចតួចណាស់ ហើយព្រមទាំងខកខានមិនបានឆ្លើយតបទៅនឹងកង្វល់ចម្បងៗ ដែលបានលើកឡើងដោយអង្គការ លីកាដូ និងសង្គមស៊ីវិលផ្សេងៗនោះឡើយ។ ស្មារតីនៃសេចក្តីព្រាងច្បាប់លើកទីពីរ នៅតែដូចគ្នានឹងសេចក្តីព្រាងលើកទីមួយជាដដែល ហើយក្នុងករណីនៃការកែប្រែមួយចំនួន ដែលបានធ្វើឡើងនៅក្នុងសេចក្តីព្រាងលើកទីពីរនេះ គឺវាធ្វើឲ្យច្បាប់នេះកាន់តែមានលក្ខណៈរឹតត្បឹត និងត្រួតត្រាខ្លាំងឡើងៗ។

របាយការណ៍សង្ខេបនេះ ធ្វើបច្ចុប្បន្នភាពព័ត៌មានក្នុងរបាយការណ៍វិភាគទីមួយរបស់អង្គការលីកាដូដែលវិភាគលើច្បាប់ស្តីពី *សមាគម និងអង្គការមិនមែនរដ្ឋាភិបាលៈ សង្គមស៊ីវិលកម្ពុជាស្ថិតក្រោមការគំរាមកំហែង*។

របាយការណ៍នេះ សរសេរឡើងវិញនូវអត្ថបទ នៃរបាយការណ៍សង្ខេបទីមួយរបស់លីកាដូ ដោយការសរសេរបន្ថែម សេចក្តីពន្យល់អត្ថាធិប្បាយលើការកែប្រែរបស់ច្បាប់ (ក្រោមចំណងជើងផ្សេងៗគ្នា)។ របាយការណ៍នេះ ក៏ផ្តល់នូវអនុសាសន៍ថ្មីៗផងដែរ។ សេចក្តីពន្យល់អត្ថាធិប្បាយភាគច្រើន ដែលមាននៅក្នុងរបាយការណ៍សង្ខេបទីមួយរបស់លីកាដូ រួមមានទាំងអនុសាសន៍ផង នៅតែមានតម្លៃសម្រាប់របាយការណ៍សង្ខេបថ្មីនេះ ដោយសារតែសេចក្តីព្រាងច្បាប់លើកទីពីរ មានការកែប្រែបន្តិចបន្តួចពីសេចក្តីព្រាងច្បាប់លើកទីមួយ។ ការកែប្រែភាគច្រើនដែលមាននៅក្នុងសេចក្តីព្រាងលើកទីពីរ គឺជាការរៀបពាក្យឲ្យល្អមើលតែប៉ុណ្ណោះ ការចុះបញ្ជីនៅតែជាលក្ខខ័ណ្ឌតម្រូវចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ហើយច្បាប់នេះ នឹងស្ថិតនៅតែជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរបំផុត មកលើសង្គមស៊ីវិលនៅប្រទេសកម្ពុជានាពេលបច្ចុប្បន្ននេះ។

## ២- និដ្ឋភាពទូទៅ

សេចក្តីព្រាងច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល[៥] ដែលបានផ្សព្វផ្សាយនា

ពេលថ្មីៗនេះ បញ្ជាក់ពីការភ័យខ្លាចអស់រយៈពេលជាយូរមកហើយ ចំពោះចេតនារបស់រដ្ឋាភិបាល ដែលចង់បានច្បាប់ប្រភេទនេះដើម្បីត្រួតត្រា ជាជាងលើកស្ទួយ និងពង្រឹងសង្គមស៊ីវិល។ សេចក្តីព្រាងច្បាប់ - ដែលស្ថិតនៅឆ្ងាយពីកំរិតកំណត់នៃបទដ្ឋានអន្តរជាតិសម្រាប់ច្បាប់ស្តី ពីវិស័យមិនទទួលផលកំរៃ - គឺជាការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សង្គមស៊ីវិលក្នុងប្រទេសកម្ពុជា ក្នុងរយៈពេលច្រើនឆ្នាំ។ នៅពេលដែលការគំរាមកំហែងអាចទំនងជាមានសភាពធ្ងន់ធ្ងរបំផុត ចំពោះអ្នកការពារសិទ្ធិមនុស្ស វាក៏មានកត្តាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរចំពោះការអភិវឌ្ឍន៍សហគមន៍ និងការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យក្នុងកំរិតទូលំទូលាយមួយ។

បើពិនិត្យមើលមួយភ្លែត សេចក្តីព្រាងច្បាប់ ហាក់ដូចជាមានភាពវិជ្ជមាន ដោយក្នុងនោះមានការលុបចោលនូវបញ្ញត្តិមានភាពជ្រុលហួសហេតុមួយចំនួន ដែលរដ្ឋាភិបាលធ្លាប់លើកយកមកជជែកពិភាក្សាក្នុងអតីតកាល។

ទោះបីជាជាយ៉ាងនេះក្តី ក៏ច្បាប់ - ទាំងមាត្រា និងស្មារតីនៃច្បាប់ - នៅតែផ្តល់អោយមាននូវទុក្ខទោសក្រៃលែងដល់សង្គមស៊ីវិល។

ក្នុងចំនោមបញ្ហាចម្បងៗនៃសេចក្តីព្រាងច្បាប់នេះមានដូចជា៖

- ការដាក់កំហិតជាខ្លាំងលើសេរីភាពខាងសមាគម
- ល័ក្ខខ័ណ្ឌតម្រូវមានលក្ខណៈស្មុគ្រស្មាញ និងពិបាក ហើយដំណើរការសំរាប់ការចុះបញ្ជី ស្របច្បាប់ជាអង្គការមិនមែនរដ្ឋាភិបាល និងសមាគម មានលក្ខណៈពិបាក និងគំរាមកំហែង
- ផ្តល់អំណាចច្រើនហួសហេតុដល់មន្ត្រីរដ្ឋាភិបាល ដែលអាចបណ្តាលអោយមានការធ្វើសេចក្តីសំរេចចិត្តតាមទំនើងចិត្ត
- ល័ក្ខខ័ណ្ឌបែបបំពាន ដែលតម្រូវឲ្យអង្គការទាំងអស់ ធ្វើរបាយការណ៍ផ្ញើជូនរដ្ឋាភិបាល ដែលជាការរំលោភដល់ឯករាជ្យភាពរបស់អង្គការ
- និងការដាក់កំហិតមិនសមហេតុផល លើអង្គការមិនមែនរដ្ឋាភិបាលបរទេស ដែលហាក់ដូចជានាំឲ្យមាននយោបាយកម្មយ៉ាងសម្បើមដល់ជំនួយមកដល់ប្រទេសកម្ពុជា។

នៅក្នុងសេចក្តីព្រាងច្បាប់នេះ បញ្ហាអាក្រក់ៗបំផុត មិនមែនជាសេចក្តីលំអិតរបស់ច្បាប់ទេ ប៉ុន្តែជាភាពខ្វះខាតរបស់ច្បាប់។ ពាក្យពេចន៍គ្មានន័យច្បាស់លាស់លើផ្នែកជាច្រើនរបស់ច្បាប់ និងភាពខ្វះខាតខាងការការពាររបស់ច្បាប់ បង្កើតឲ្យមានវិសាលភាពយ៉ាងធំ សំរាប់មន្ត្រីរដ្ឋាភិបាលប្រើប្រាស់ច្បាប់តាមទំនើងចិត្ត និងដោយភាពជ្រើសរើស ដើម្បីដាក់កំហិត និងត្រួតត្រាលើការងាររបស់ក្រុមសង្គមស៊ីវិល ហើយជាពិសេស គឺដើម្បីគំរាមកំហែង និងបង្កជាឧបសគ្គដល់អង្គការទាំង

ឡាយណាដែលមិនមែនជាការពេញចិត្តរបស់រដ្ឋាភិបាល។

អ្វីដែលជាការព្រួយបារម្ភណ៍បំផុត គឺច្បាប់ដាក់កំហិតដែលមិនធ្លាប់មានពីមុនមកលើសេរីភាពខាងសមាគម ដែលរួមមាន ការតម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ត្រូវតែចុះបញ្ជីជាចាំបាច់ និងការហាមឃាត់ "ការធ្វើសកម្មភាព" ដោយក្រុមទាំងឡាយណាដែលមិនបានចុះបញ្ជី។

លើសពីនេះទៅទៀត ការណ៍ដែលគោលបំណងមួយ នៃគោលបំណងទាំងអស់របស់ច្បាប់ (មាត្រា ២) ចែងអះអាងថា ជាការលើកកម្ពស់ការអនុវត្តសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋខ្មែរក្នុងការបង្កើតសមាគម អង្គការមិនមែនរដ្ឋាភិបាលដែលតាមពិតទៅវាជាការដាក់ឲ្យមាននូវឧបសគ្គច្រើន ចំពោះការបង្កើតសមាគម និងអង្គការទៅវិញទេ។ ជាជាងជាប្រព័ន្ធមួយដែលមានភាពសាមញ្ញ តម្លាភាព និងងាយស្រួលក្នុងការចុះបញ្ជី ច្បាប់នេះ ធ្វើឲ្យមើលឃើញពីដំណើរការស្មុគ្រស្មាញជាច្រើន សំរាប់អង្គការ ជាពិសេសអង្គការតូចៗ បែបសហគមន៍ ដែលធ្វើការងារនៅថ្នាក់មូលដ្ឋានផ្ទាល់ - នឹងត្រូវពុះពារដើម្បីជំនះបានការលំបាកដែលតម្រូវដោយច្បាប់នេះ។

ច្បាប់អោយអំណាចយ៉ាងទូលំទូលាយ និងឯកសិទ្ធិពិសេស ដល់មន្ត្រីរដ្ឋាភិបាល - ដោយគ្មានផ្តល់សិទ្ធិដើម្បីប្តឹងជំទាស់នឹងសេចក្តីសម្រេចរបស់មន្ត្រីរដ្ឋាភិបាលទេ។ សិទ្ធិអំណាចនេះ មានដូចជា អំណាចក្នុងការសម្រេចថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាលមួយណាដែលអាច ឬមិនអាចចុះបញ្ជីបាន និងដែលអាច ឬមិនអាច ស្ថិតនៅដោយស្របច្បាប់បាន[៦] និងផ្អាកដល់សកម្មភាពអង្គការដែលបានចុះបញ្ជី រយៈពេលពីមួយទៅបីខែ (ឬជាអចិន្ត្រៃយ៍ ចំពោះអង្គការមិនមែនរដ្ឋាភិបាលបរទេស)[៧]។ ជាការគំរាមកំហែងថែមទៀតនោះ គឺច្បាប់ចែងរបៀបបញ្ជិតបញ្ចៀង (ដោយមិនមានភាពជាក់លាក់) អំពីលទ្ធភាពខាងវិធានការផ្លូវច្បាប់ប្រឆាំងនឹងអង្គការមិនមែនរដ្ឋាភិបាល ឬ សមាគម ដែលចាត់ទុកថាបានប្រព្រឹត្តិល្មើសនឹងលក្ខន្តិកៈ ឬអនុស្សរណៈជាមួយរដ្ឋាភិបាល[៨] និងខាងតុលាការមានលទ្ធភាពធ្វើការរំលាយ ឬបញ្ចប់សុពលភាពដោយបង្ខំ ចំពោះអង្គការក្នុងស្រុក និងអង្គការបរទេស[៩]។

បទប្បញ្ញត្តិទាំងនេះ (និងបទប្បញ្ញត្តិដទៃទៀត) ក្នុងសេចក្តីព្រាងច្បាប់ ត្រូវតែបានពិនិត្យមើលដោយគិតទៅដល់បរិបទនៃប្រទេសកម្ពុជា ដែលក្នុងនោះរួមមានការខ្វះខាតនូវ តុលាការដែលឯករាជ្យ និងស្ថាប័នផ្សេងទៀតសំរាប់ទប់អំណាចរបស់នីតិប្រតិបត្តិ ហើយនិងស្លាកស្នាមនៃប្រវត្តិជាយូរលង់មកហើយនៃការធ្វើទុក្ខបុកម្នេញរបស់រដ្ឋាភិបាល - តាមរយៈការប្រើប្រាស់ច្បាប់ និងមធ្យោបាយផ្សេងៗ មិនបានត្រឹមត្រូវ - ចំពោះអ្នកការពារសិទ្ធិមនុស្ស និងសមាជិកសង្គមស៊ីវិលដទៃទៀត។

ជាការសំខាន់ណាស់ដើម្បីទទួលស្គាល់ថា ច្បាប់នេះទំនងជាត្រូវគេប្រើប្រាស់ដោយជ្រើសរើស - ប្រឆាំងនឹងអង្គការជាក់លាក់មួយចំនួន ដែលរដ្ឋាភិបាលមិនពេញចិត្ត ដោយសារហេតុផលមួយ ឬហេតុផលដទៃទៀត - ឧទាហរណ៍ ជាជាងការបិទអង្គការរាប់រយតែម្តង។ នេះមិនបានធ្វើឲ្យចរិកប្រកបដោយល្បិចកលរបស់ច្បាប់នេះថមថយទេ ការប្រើប្រាស់ច្បាប់តាមទំនើងចិត្តដើម្បីរុកគួន និងគំរាមកំហែងអង្គការជាក់លាក់មួយចំនួន (ដូចជាអង្គការទាំងឡាយណាដែលបង្ហាញនូវទស្សនៈរិះគន់ដល់រដ្ឋាភិបាល) នឹងនាំឲ្យមានផលប៉ះពាល់យ៉ាងខ្លាំងដល់សង្គមស៊ីវិលទាំងមូល។ លទ្ធផលជាចុងក្រោយគឺការភ័យខ្លាចមានកាន់តែខ្លាំងឡើងៗ ហើយហេតុដូច្នេះនាំមកនូវការត្រួតត្រាខ្លួនដោយខ្លួនឯង និងការដាក់កំហិតដោយស្ម័គ្រចិត្ត លើការធ្វើសកម្មភាពនៃអង្គការមិនមែនរដ្ឋាភិបាល សមាគម និងក្រុមដទៃទៀតក្នុងសង្គម។

ក្រុមសង្គមស៊ីវិលទាំងឡាយដែលស្ថិតក្នុងគ្រោះថ្នាក់ដោយផ្ទាល់ ក្រោមច្បាប់នេះ រួមមាន៖

- សមាគម ឬអង្គការ ដែលធ្វើការងារលើការតស៊ូមតិ និង/ឬ ធ្វើសកម្មភាពឃ្លាំមើលរដ្ឋាភិបាល - ដែលកិច្ចការនេះជាតួនាទីយ៉ាងសំខាន់របស់សង្គមស៊ីវិលនៅក្នុងប្រទេសនានា។
- អង្គការ និងសមាគមតូចៗ ដែលគ្មានលទ្ធភាពបំពេញនូវ ល័ក្ខខ័ណ្ឌដ៏តឹងតែងតម្រូវដោយច្បាប់សំរាប់ការចុះបញ្ជី ហេតុនេះ អង្គការ និងសមាគមទាំងនោះនឹងគ្មានលទ្ធភាព បន្តទទួលស្គាល់ដោយច្បាប់នូវភាពស្របច្បាប់។
- ក្រុមមិនផ្លូវការ ឬក្រុមពាក់កណ្តាលផ្លូវការ និងបណ្តាញនៅថ្នាក់មូលដ្ឋាន (ជាឧទាហរណ៍ ក្រុមនៃកសិករ ប្រជានេសាទ ឬជនជាតិភាគតិច) ដែលមិនមានបំណង និងមិនចង់ក្លាយជាអង្គការមិនមែនរដ្ឋាភិបាល ឬសមាគម ដែលក្រុមទាំងនេះ អាចនឹងត្រូវបានអាជ្ញាធរមូលដ្ឋានណែនាំឲ្យបញ្ឈប់សកម្មភាពរបស់ពួកគេ ដោយទាញយកមកប្រើនូវល័ក្ខខ័ណ្ឌ តម្រូវឲ្យចុះបញ្ជីជាចាំបាច់សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល (ដែលល័ក្ខខ័ណ្ឌ តម្រូវទាំងពីរត្រូវបានកំណត់និយមន័យទូលំទូលាយពេកនៅក្នុងច្បាប់) និងការហាមប្រាមលើ "ការធ្វើសកម្មភាព" នៃអង្គការ សមាគមដែលមិនបានចុះបញ្ជី។

ច្បាប់នេះនឹងធ្វើឲ្យចុះខ្សោយដល់ការអភិវឌ្ឍសហគមន៍ និងការចូលរួមក្នុងដំណើរការប្រជាធិបតេយ្យ នៅក្នុងកំរិតទូលំទូលាយមួយ ដែលរួមមានសក្តានុពលនៃផលប៉ះពាល់ធ្ងន់ធ្ងរលើលទ្ធភាពនៃសហគមតាមមូលដ្ឋាន ដើម្បីចូលរួមក្នុងការអភិវឌ្ឍន៍របស់ខ្លួនដោយខ្លួនឯងផ្ទាល់។ អ្វីដែលមានគ្រោះថ្នាក់ខ្លាំងនោះគឺថា មន្រ្តីមូលដ្ឋាននឹងប្រើប្រាស់ច្បាប់នេះដើម្បីគាបសង្កត់លើសកម្មភាពរបស់ក្រុម សហគមតាមមូលដ្ឋាន ឬបណ្តាញ ឬបុគ្គលជាសមាជិកសហគមដោយខ្លួនគេផ្ទាល់នូវសកម្មភាពទាំងឡាយណាដែលអាជ្ញាធរ "មិនត្រូវការ"។ ក្រុមអ្នកភូមិ អាចត្រូវបានចោទប្រកាន់ពីការធ្វើសកម្មភាពមិនស្របច្បាប់ ដោយសារតែពួកគេមិនបានចុះបញ្ជីជាសមាគម បើសិន

ជាក្នុងករណី ដែលពួកគេជួបប្រជុំគ្នា ដើម្បីពិភាក្សា ឬស្វែងរកការគាំទ្រលើបញ្ហាសំខាន់ចាំបាច់ ដែលពាក់ព័ន្ធនឹងពួកគេ - ជាឧទាហរណ៍ដូចជាការចែកចាយជំនួយរបស់អង្គការស្បៀងអាហារពិភពលោក ផែនការអភិវឌ្ឍដែលលើកឡើងដោយក្រុមប្រឹក្សាឃុំ/សង្កាត់ក្នុងមូលដ្ឋានរបស់ពួកគេ ឬក៏ការរំលោភយកដីធ្លីរបស់ពួកគេ ពីសំណាក់ ក្រុមហ៊ុនឯកជន។ល។

ដូចគ្នានេះដែរ ច្បាប់នេះអាចមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋប្រភេទដទៃទៀត ដែលចូលរួមគ្នា ដើម្បីតំណាងឲ្យផលប្រយោជន៍រួមរបស់ពួកគេ ឧទាហរណ៍ និស្សិតមហាវិទ្យាល័យ អ្នករត់ម៉ូតូកង់បី ឬម៉ូតូឌុប អ្នកនៅរស់រានមានជីវិតពីអំពើរំលោភ ឬអំពើហិង្សាក្នុងគ្រួសារ ឬក៏អ្នកផ្ទុកមេរោគអេដស៍-ជំងឺអេដស៍។ បើសិនជាពួកគេជួបជុំគ្នាដើម្បីពិភាក្សាពីបញ្ហារបស់ពួកគេ ដើម្បីព្យាយាមជួយគ្នាទៅវិញទៅមក និងស្វែងរកការគាំទ្រចំពោះសេវាដែលពួកគេត្រូវការ នោះពួកគេអាចនឹងត្រូវបានបញ្ជាឲ្យរំសាយ ឬបញ្ឈប់សកម្មភាព ឬក៏តម្រូវឲ្យធ្វើតាមនិតិវិធី (ស្មុគស្មាញ) ចុះបញ្ជីជាសមាគម ឬអង្គការ។ ម្តងទៀត ដំណើរការនេះនឹងត្រូវប្រព្រឹត្តទៅដោយ ជ្រើសរើសការយាយីបែបនេះ ហាក់ដូចជានឹងមិនធ្វើប្រឆាំងចំពោះក្រុមណាដែលរដ្ឋាភិបាលគិត ថាមិនមែនជាការបំភិតបំភ័យ ឬរំខានដល់ខ្លួន ប៉ុន្តែនឹងយាយីលើក្រុមដទៃ ឧទាហរណ៍ក្រុមទាំងឡាយណា ដែលរិះគន់រដ្ឋាភិបាលពីការខ្វះខាតសេវាកម្មសំរាប់ពួកគេ។

គ្រោះថ្នាក់មានកំរិតខ្ពស់ចំពោះការប្រើប្រាស់ច្បាប់នេះ ដោយមិនត្រឹមត្រូវតាមរបៀបទាំងអស់នេះ ដោយសារតែលំហរដែលមានសម្រាប់ការចូលរួមគ្នាដើម្បីស្វែងរកការគាំទ្រចំពោះផលប្រយោជន៍របស់ប្រជាពលរដ្ឋ មានការដាក់កំហិតយ៉ាងចង្អៀតរួចទៅហើយ ជាពិសេសនៅថ្នាក់ភូមិ។ បុគ្គល និងក្រុម ដែលព្យាយាមធ្វើឲ្យមានសំលេងលើបញ្ហាដែលប៉ះពាល់ដល់អាយុជីវិតពួកគេ- ជាពិសេសបើសិនជាពួកគេជំទាស់នឹងការចាប់យកដីធ្លីរបស់ពួកគេពីអ្នកជំនួញ អ្នកមានអំណាច មន្ត្រីរដ្ឋាភិបាល ឬអ្នកដទៃទៀត - ជាញឹកញយប្រឈមនឹងការគំរាមកំហែង យាយី ចាប់ខ្លួន និងឃុំខ្លួន។ ជាឧទាហរណ៍នៃការដែលច្បាប់ត្រូវបានគេប្រើដោយបំភាន់បន្លំ ដើម្បីប្រព្រឹត្តលើប្រជាពលរដ្ឋបែបនេះ គឺយើងមិនចាំបាច់មើលហួសឆ្ងាយទេ គឺមើលត្រឹមតែលើសកម្មជន សហគមចំនួន៣៧នាក់ ដែលកំពុងតែជាប់ពន្ធនាគារ (គិតត្រឹមថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០) ដោយសារតែកិច្ចខិតខំដោយអហិង្សារបស់ពួកគេ ដើម្បីជួយសហគមពួកគេព្យាយាមការពារដីធ្លី របស់ពួកគេ ឬធនធានធម្មជាតិប៉ុណ្ណោះ។

ទន្ទឹមគ្នានេះដែរ ការបញ្ចេញឲ្យដឹង គឺជាលក្ខណៈដែលសេចក្តីព្រាងច្បាប់នេះ ត្រូវបានគេផ្សព្វផ្សាយជាសាធារណៈ ដែលជាការបង្ហាញពីចេតនារបស់រដ្ឋាភិបាល។ ក្រសួងមហាផ្ទៃ ដែលជាអ្នកធ្វើសេចក្តីព្រាងច្បាប់នេះ បានបញ្ចេញសេចក្តីព្រាងច្បាប់ នៅថ្ងៃ១៥ ខែធ្នូ ដោយមានរយៈពេលតែ ៩ថ្ងៃប៉ុណ្ណោះ មុនពេលដែលក្រសួងមហាផ្ទៃ ដែលកាលដើមឡើយ មានបំណងធ្វើការជួបប្រជុំ

ដែលគេហៅថា "ពិគ្រោះយោបល់ថ្នាក់ជាតិ" នៅក្នុងទីក្រុងភ្នំពេញលើសេចក្តីព្រាងច្បាប់[១០]។ សម្រាប់រយៈពេលខ្លីបំផុតដែលក្រសួងមហាផ្ទៃ គ្រោងផ្តល់ដល់សង្គមស៊ីវិល និងសាធារណៈជនដើម្បីពិនិត្យសេចក្តីព្រាងច្បាប់នេះ ក៏ដូចជាចេតនារបស់ខ្លួនដើម្បីធ្វើ "ការពិគ្រោះយោបល់ថ្នាក់ជាតិ" តាមរបៀបនៃការជួបប្រជុំតែរយៈពេលមួយថ្ងៃក្នុងរាជធានី បង្ហាញឲ្យឃើញតិចតួចពីបំណងចង់ឲ្យមានការពិគ្រោះយោបល់ប្រកបដោយអត្ថន័យលើច្បាប់នេះ។

# ៣- បញ្ហាចម្បងៗរបស់សេចក្តីព្រាងច្បាប់

របាយការណ៍នេះមិនធ្វើការទិតៀនលើមាត្រានីមួយៗនៃសេចក្តីព្រាងច្បាប់នោះទេ ប៉ុន្តែទោះជាយ៉ាងណា ក៏ច្បាប់នេះខ្វះខាតខ្លឹមសារច្រើន ដែលគួរតែជាការគោះជួង ជាសញ្ញាបន្លឺដល់អ្នកគ្រប់គ្នា ដែលចាប់អារម្មណ៍ពីឯករាជ្យភាពរបស់សង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។ ផ្នែកដែលជាកង្វល់ត្រួតគ្នាទាំងនេះ រួមមាន:

***ការដាក់កំហិតជាខ្លាំងលើសេរីភាពខាងសមាគម:*** សិទ្ធិរបស់ប្រជាពលរដ្ឋកម្ពុជាមានសេរីភាពខាងសមាគមដែលការពារជាអន្តរជាតិ ត្រូវបានដាក់កំរិតជ្រុលហួសហេតុដោយច្បាប់ តាមមធ្យោបាយផ្សេងៗ រួមមានល័ក្ខខ័ណ្ឌតម្រូវឲ្យចុះបញ្ជីជាចាំបាច់ ដូចដែលបានពោលខាងលើ។ ដូចដែលអង្គការអន្តរជាតិជំនាញមួយបានធ្វើការកត់សំគាល់ "ថាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលអាចត្រូវបង្កើតជានីតិបុគ្គល នោះមិនមែនមានន័យថា បុគ្គលអាចតម្រូវឲ្យបង្កើតជានីតិបុគ្គលដើម្បីអនុវត្តសេរីភាពខាងសមាគមនោះទេ[១១]។" (នៅក្នុងប្រទេសអភិវឌ្ឍជាច្រើន អង្គការមិនមែនរដ្ឋាភិបាល សមាគម ឬក្រុមដទៃទៀត ស្ម័គ្រចិត្តជ្រើសរើសយកការចុះបញ្ជី និងក្លាយទៅជានីតិបុគ្គលពីព្រោះវាជាផលប្រយោជន៍សំរាប់ពួកគេក្នុងការចុះបញ្ជី - ពួកគេនឹងមានលក្ខណ:សម្បត្តិទទួលបានផលប្រយោជន៍ ដូចជា ការលើកលែងពន្ធ ជាឧទាហរណ៍ ឬក៏វាបង្កលក្ខណ:ងាយស្រួលដល់ពួកគេក្នុងការរកមូលនិធិ។)

ជាបន្ថែមទៀត ដូចមានពិភាក្សាលំអិតខាងក្រោម ដំណើរការចុះបញ្ជីមានលក្ខណ:ស្មុគស្មាញ និងផ្តល់អំណាចច្រើនហួសហេតុដល់មន្ត្រី (រួមទាំងការបដិសេធការចុះបញ្ជី ដោយគ្មានផ្តល់ឲ្យមានសិទ្ធិប្តឹងតវ៉ា) ក៏ជាការរំលោភដោយផ្ទាល់លើសេរីភាពខាងសមាគម។ វាក៏ជាការរំលោភដោយផ្ទាល់លើសេរីភាពខាងសមាគមដូចគ្នាផងដែរ ការចែងកំណត់ របស់ពង្រាងច្បាប់អំពីចំនួនមនុស្សប៉ុន្មាននាក់ដែលត្រូវតែចូលរួមពាក់ព័ន្ធក្នុងការបង្កើតអង្គការក្រៅរដ្ឋាភិបាល ឬសមាគម។ ដូចជាការកំណត់ក្នុងច្បាប់ថា ត្រូវមានអ្នកផ្តួចផ្តើមយ៉ាងហោចណាស់បីនាក់ ព្រមព្រៀងគ្នាបង្កើតអង្គការមិនមែនរដ្ឋាភិបាល ខណ:ដែលការបង្កើត សមាគមត្រូវមានសមាជិក ស្ថាបនិកចំនួន ២១នាក់ យ៉ាងតិច[១២]។ (បើប្រៀបធៀបជាមួយក្រុមហ៊ុន ការបង្កើតក្រុមហ៊ុន មួយអាចត្រូវបានបង្កើត

ឡើង និងចុះបញ្ជីនៅក្នុងប្រទេស កម្ពុជាដោយត្រឹមតែមានបុគ្គលមួយរូបប៉ុណ្ណោះ)[១៣]។

## ►►► សេចក្តីអត្ថាធិប្បាយលើពង្រាងច្បាប់ លើកទីពីរ

*សេចក្តីព្រាងច្បាប់លើកទីពីរនេះ មិនបានឆ្លើយតបទៅនឹងកង្វល់ណាមួយនៃកង្វល់នានាខាងលើទេ ក្នុងនេះមាន ទាំងការតម្រូវឲ្យចុះបញ្ជីជាចាំបាច់ **(សូមមើលមាត្រាទី ៦)**។ អង្គការលីកាដូជឿជាក់ថា ការចុះបញ្ជីជាចាំបាច់នេះ គឺជាការរំលោភសិទ្ធិមានសេរីភាពក្នុងការបង្កើតសមាគមរបស់ប្រជាពលរដ្ឋកម្ពុជា ដោយសារតែលក្ខណៈហួសហេតុនៃការិយាធិបតេយ្យ និងលក្ខណៈត្រួតត្រា ដែលច្បាប់នេះបានដាក់ទៅលើ ក្រុមអង្គការសង្គមស៊ីវិល។*

*ជាងនេះទៅទៀត លីកាដូមានយល់ថា ច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដោយឡែកមួយគឺមិនមានភាពចាំបាច់ឡើយ ដោយសារ ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលនៅកំពុងតែរង់ចាំការប្រកាសឲ្យប្រើ ផ្តល់នូវការចុះបញ្ជីដោយស្ម័គ្រចិត្ត ព្រមទាំងផ្តល់ឲ្យមាននូវបទប្បញ្ញត្តិគ្រប់គ្រាន់ ចំពោះគ្រប់អង្គការ ឬស្ថាប័ននិតិបុគ្គលទាំងអស់ - ទាំងចំពោះអង្គការមិនរកកម្រៃ និងអង្គការរកកម្រៃ។ រដ្ឋាភិបាលមិនទាន់បានផ្តល់ការពន្យល់ ដែលគួរឲ្យជឿបាននៅឡើយ ពីមូលហេតុនៃភាពចាំបាច់នៃការមានច្បាប់ ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយឡែក។*

***មាត្រា ៣** ដែលកំណត់ពីពីវិសាលភាពរបស់ច្បាប់ បច្ចុប្បន្ននេះ សរសេរបែបនិយាយសំដៅទៅ "អង្គការមានមូលដ្ឋាននៅតាមសហគមន៍ ដែលបង្កើតនៅតាមមូលដ្ឋាន មិនស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់នេះ ហើយធ្វើសកម្មភាពស្របច្បាប់នានាជាផរមាន ដើម្បីជួយគ្នាទៅវិញទៅមក" ដែលត្រូវបានលើកលែងចេញពីច្បាប់។ នៅក្នុងភាសាខ្មែរ មាត្រា ៦ ដែលចែងពីការលើកលែងចេញពីច្បាប់ គឺសំដៅទៅលើ "អង្គការមហាជន" ជាពាក្យដែលគេប្រើនៅក្នុងសម័យកុម្មុយនិស ឆ្នាំ១៩៨០ ដែលសំដៅលើ "អង្គការរបស់ប្រជាជន"។*

*ហេតុដូច្នេះ ទិដ្ឋភាពសំខាន់នៃមាត្រានេះ គឺមិនច្បាស់លាស់។ តើ "អង្គការមហាជន" មានន័យពិតប្រាកដយ៉ាងដូចម្តេច? ហើយតើឃ្លាដែលថា "បានបង្កើតនៅមូលដ្ឋាន" មានន័យយ៉ាងដូចម្តេច? ប្រសិនបើសមាគមក្នុងស្រុកដែលមានសមាជិកស្ថាបនិកជាជនជាតិខ្មែរតិចជាង ១១នាក់ តើវាអាច ជាសមាគមដែលបង្កើតឡើងដោយ "មិនស្របតាមល័ក្ខខ័ណ្ឌ ដែលមានចែងក្នុងច្បាប់" ហើយហេតុដូច្នេះត្រូវបានលើកលែងចេញពីច្បាប់ ដែរឬទេ? ប្រសិនបើអង្គការសង្គមស៊ីវិលមិនផ្លូវការមួយ ត្រូវបានបង្កើតឡើងដោយសមាជិកស្ថាបនិក និងតំណាង មកពីភូមិ និងឃុំ ក៏ប៉ុន្តែធ្វើបណ្តាញ និងធ្វើសកម្មភាពការងារ ជាមួយអង្គការមិនមែនរដ្ឋាភិបាល ឬ សម្ព័ន្ធអង្គការនានា នៅ*

*ថ្នាក់ខេត្ត និងថ្នាក់ជាតិ តើអង្គការសង្គមស៊ីវិលនេះបង្កើតឡើង "មិនស្របតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ដែរឬ?*

*ភាពស្រពិចស្រពិលដែលមាននៅក្នុងមាត្រា ៣ ពិតជានឹងនាំទៅរកការអនុវត្តន៍ច្បាប់តាមទំនើងចិត្ត និងដោយការជ្រើសរើស។ រដ្ឋាភិបាលត្រូវតែបញ្ជាក់ឲ្យច្បាស់ពី និយមន័យ និងបញ្ជាក់ឲ្យបានជាក់លាក់ពីវិសាលភាពនៃ ក្រុមអង្គការសង្គមស៊ីវិល ដែលត្រូវបានលើកលែងដោយច្បាប់តាមមាត្រា៣ ដោយហេតុថា មាត្រា៦ តម្រូវឲ្យសមាគម ឬអង្គការ មិនមែនរដ្ឋាភិបាល ចុះបញ្ជី ឬចុះអនុស្សរណៈ ដើម្បីធ្វើសកម្មភាពដោយស្របច្បាប់នៅក្នុងប្រទេសកម្ពុជា។*

***មាត្រា ៩*** *ដែលតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកទាំងអស់ ដែលធ្វើសកម្មភាពនៅក្នុងប្រទេសកម្ពុជា ត្រូវមានស្ថាបនិកជនជាតិខ្មែរចំនួន ៣នាក់ នៅតែមិនមានការកែប្រែ។ មាត្រា ៨ ដែលចែងអំពីលក្ខខ័ណ្ឌសម្រាប់ការចុះបញ្ជី សមាគម បានកាត់បន្ថយចំនួនសមាជិកស្ថាបនិកជនជាតិខ្មែរ ដែលចាំបាច់សម្រាប់ការបង្កើតសមាគម ពីចំនួន ២១នាក់ មកនៅត្រឹម ១១ នាក់ និងបានកាត់បន្ថយចំនួនសមាជិកថ្នាក់ដឹកនាំពី ៧នាក់ មកនៅត្រឹម ៥នាក់។ ការកែប្រែដ៏តិចតួច នេះនៅតែរំលោភលើសេរីភាពក្នុងការបង្កើតសមាគម និងមិនបានសម្រាលដល់បន្ទុកនៃដំណើរការចុះបញ្ជីសមាគមក្នុងស្រុកទេ។ ប្រសិនបើសមាគម ឬអង្គការមិនមែនរដ្ឋាភិបាល មានចំនួនសមាជិកស្ថាបនិក ឬសមាជិកដឹកនាំតិចជាងចំនួន ដែលតម្រូវឲ្យមាននេះ តើអង្គការ ឬសមាគមទាំងនេះ នឹងនៅតែតម្រូវឲ្យចុះបញ្ជី ដើម្បីអាចប្រតិបត្តការនៅក្នុងប្រទេសកម្ពុជាដែរឬទេ? ច្បាប់នេះមិន ច្បាស់លាស់លើចំនុចនេះ។*

***ល័ក្ខខ័ណ្ឌតម្រូវ និងដំណើរការចុះបញ្ជីដ៏ស្មុគ្រស្មាញ:*** ដូចគ្នានឹងការទាមទារ ល័ក្ខខ័ណ្ឌយ៉ាងច្រើនចំពោះអង្គការដែលចង់ចុះបញ្ជី ច្បាប់នេះផ្តល់នូវដំណើរការចុះបញ្ជីដ៏ពន្យាពេល។ ការចុះបញ្ជីអង្គការមួយ អាចចំណាយពេលរហូតដល់ ៩៥ថ្ងៃ នៃថ្ងៃធ្វើការងារ (ជាអប្បរមា ចំនួន៩សប្តាហ៍ ដោយគ្មានគិតពី ថ្ងៃឈប់សម្រាកជាតិ) ឬក៏យូរជាងនេះ បើសិនជាមន្រ្តីរដ្ឋាភិបាលដែលមានភារកិច្ចលើដំណើរការ ចុះបញ្ជីនេះដេញដោលពីនីត្យានុកូលភាពនៃសំណុំបែបបទ[១៤]។

ល័ក្ខខ័ណ្ឌលំអិតដែលតម្រូវចំពោះអ្នកដាក់សំណុំបែបបទ គឺជាឧបសគ្គចម្បងមួយចំពោះអង្គការជាច្រើន ជាពិសេសអង្គការតូចៗដែលមានសមាជិកតាមតំបន់គោលដៅការងារ និងអង្គការនានា ដែលមានមូលដ្ឋាននៅតំបន់ជនបទ[១៥]។ ដូចជាការតម្រូវកំណត់លើចំនួនមនុស្ស ដែលត្រូវតែមាន ដើម្បីបង្កើតអង្គការ (ដូចដែលបានលើកឡើងខាងលើ) ដែលអ្នកដាក់សំណុំបែបបទត្រូវភ្ជាប់ជាមួយនូវឯកសារយ៉ាងច្រើនដើម្បីដាក់ជូនរដ្ឋាភិបាល[១៦] ដែលរួមមាន៖ លក្ខន្តិកៈ សម្រាប់អង្គការ[១៧] ឈ្មោះ និងអាសយដ្ឋានរបស់ស្ថាបនិកទាំងអស់ លិខិតបញ្ជាក់ពីអាសយដ្ឋាន ដោយមានការទទួល

ស្គាល់ពីមេឃុំ/ចៅសង្កាត់នៃ "ទីស្នាក់ការកណ្ដាល"[១៨] របស់អង្គការ ប្រវត្តិរូបសង្ខេបរបស់ថ្នាក់ដឹកនាំអង្គការ (យ៉ាងហោចណាស់ចំនួន៧នាក់ ក្នុងករណីសមាគម) ក្នុងម្នាក់ពីរច្បាប់ និងមានបិទរូបថតទំហំ ៤x៦ និង (សម្រាប់តែអង្គការក្រៅរដ្ឋាភិបាល) លិខិតប្រកាស គណនីធនាគារ។ ក្នុងបរិបទនៃប្រទេសកម្ពុជា ល័ក្ខខ័ណ្ឌតម្រូវទាំងនេះ - ការបង្ហាញ ពីអាសយដ្ឋាន ផ្តល់ឲ្យនូវរូបថត លិខិតបញ្ជាក់ចេញដោយមេឃុំ ឬអភិបាលស្រុក - នឹងនាំឲ្យមានការភ័យខ្លាច ក្នុងចំនោមអ្នកដាក់សំណុំបែបបទ។ (ជាបន្ថែមទៀត ការតម្រូវចំពោះ "ប្រវត្តិសង្ខេប" នៃថ្នាក់ដឹកនាំ អាចបញ្ជាក់បានថារដ្ឋាភិបាលអាចពិនិត្យផ្ទៀងផ្ទាត់លើអ្នកដាក់សំណុំឯកសារទាំងអស់ តាមមធ្យោបាយណាមួយជាមិនខាន - ជាការរំលោភលើសេរីភាពខាងសមាគម ដែលអនុវត្តចំពោះជនគ្រប់រូប មិនមែនចំពោះតែជនទាំងឡាយណាដែលរដ្ឋាភិបាលចាត់ទុកថា សមស្របនោះទេ។)

ការិយាធិបតេយ្យមួយកំរិតថែមទៀត និងជាបន្ទុកដ៏ធ្ងន់លើអង្គការ និងសមាគមនានា ត្រូវបានផ្តល់ឲ្យដោយល័ក្ខខ័ណ្ឌតម្រូវរបស់ច្បាប់ដែលថា "សម្ព័ន្ធ" (នៃអង្គការក្រៅរដ្ឋាភិបាល ឬសមាគមដែលបានចុះបញ្ជី ដែល "ចូលរួមសហការជាមួយគ្នាដើម្បីគោលបំណងរួមមួយ") ក៏ត្រូវតែធ្វើតាមរយៈដំណើរ ការចុះបញ្ជីស្រដៀងគ្នានេះដែរ។

(បទប្បញ្ញត្តិស្តីពីសម្ព័ន្ធ នៅក្នុងច្បាប់នេះ មានភាពមិនច្បាស់លាស់ ដោយរំលោភសិទ្ធិ និងរំលោភសេរីភាពខាងសមាគម។ ភាពមិនច្បាស់លាស់របស់ច្បាប់នេះគឺនៅត្រង់ថា នៅពេលណាដែលសម្ព័ន្ធអង្គការត្រូវតម្រូវឲ្យចុះបញ្ជី។ ជាបន្ថែមទៀត ខណៈដែលគេអនុញ្ញាតិឲ្យអង្គការ "ធ្វើសហប្រតិបត្តិការ ដើម្បីអនុវត្តគម្រោងស្របច្បាប់ណាមួយ" ដោយគ្មានការបង្កើតជាសម្ព័ន្ធជាផ្លូវការទេ គឺវាតម្រូវឲ្យអង្គការទាំងនោះជូនដំណឹងមកក្រសួងមហាផ្ទៃអំពីកិច្ចសហការនេះ។ វាមិនបានកំណត់ពីអ្វីដែលបង្កើតជា "គម្រោង"[១៩] នោះទេ។ បទប្បញ្ញត្តិទាំងនេះ លើកឡើងពីលទ្ធភាពដែលអង្គការពីរ ឬច្រើន ដែលសហការគ្នា តាមមធ្យោបាយនានា - ជាឧទាហរណ៍ ការធ្វើសិក្ខាសាលា ឬការចេញរបាយការណ៍ ឬសេចក្តីថ្លែងការណ៍សារព័ត៌មានរួមគ្នា - អាចត្រូវរងការ ចោទប្រកាន់ពីការមិនគោរពតាមល័ក្ខខ័ណ្ឌតម្រូវនៃច្បាប់ស្តីពីការជូនដំណឹង ឬការចុះបញ្ជី។[២០])

ជាចុងក្រោយ គឺនៅក្នុងអ្វីដែលជាការដាក់បន្ទុករដ្ឋបាលយ៉ាងធ្ងន់ ទាំងចំពោះរដ្ឋាភិបាលទាំងក្រុមសង្គមស៊ីវិល ដែលច្បាប់នេះតម្រូវថា សមាគម អង្គការក្រៅរដ្ឋាភិបាល និងសម្ព័ន្ធសមាគម អង្គការមិនមែនរដ្ឋាភិបាល ដែលមានស្រាប់ទាំងអស់ ត្រូវតែរៀបចំសំណុំលិខិតសុំចុះបញ្ជីសារជាថ្មី ក្នុងរយៈពេល៦ខែ បន្ទាប់ពីច្បាប់នេះចូលជាធរមាន បើមិនដូច្នេះទេពួកគេនឹងគ្មានសិទ្ធិធ្វើសកម្មភាពទៀតទេ។ អង្គការមិនែមនរដ្ឋាភិបាលបរទេស ដែលមិនបានចុះអនុស្សរណៈ ជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចគ្នានេះដែរនឹងត្រូវរៀបចំធ្វើធ្វើសំណុំបែបបទ ចុះអនុស្សរណៈតែម្តង ចំណែកឯអង្គការបរទេសទាំងឡាយណា ដែលមានអនុស្សរណៈ

រួចហើយ នឹងនៅមានសុពលភាព អនុវត្តបន្ត រហូតដល់ផុតពេលកំណត់នៃអនុស្សរណៈ[២១]។

## ►►► សេចក្តីអត្ថាធិប្បាយលើពង្រាងច្បាប់លើកទីពីរ

*__មាត្រា ១០ ដល់មាត្រា ១៤__ រក្សាទុកនៅដដែលដោយមិនមានការកែប្រែ។ ខណៈពេលជាមួយគ្នានេះ មាត្រាមួយចំនួន ត្រូវបានកែប្រែ ហើយដែលការកែប្រែនេះធ្វើឲ្យ ល័ក្ខខ័ណ្ឌ និងដំណើរការនៃការចុះបញ្ជី កាន់តែមានបន្ទុកធ្ងន់ធ្ងរឡើង និងពោពេញទៅដោយភាពគ្រោះថ្នាក់។*

*ជាឧទាហរណ៍ __មាត្រា ១៥__ នៃសេចក្តីព្រាងច្បាប់លើកទីពីរ បង្ហាញថា អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវតែប្រគល់លិខិតប្រកាសគណនីធនាគារ ក្នុងអំឡុង៣០ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសេចក្តីជូនដំណឹងពីការចុះបញ្ជី។ សេចក្តីព្រាងច្បាប់លើកទីពីរនេះ ឥឡូវមានចែងយ៉ាងជាក់លាក់ថា ការខកខាន មិនបានប្រគល់លិខិតប្រកាសគណនីធនាគារនេះ នឹងត្រូវលុបឈ្មោះរបស់អង្គការនោះចេញពីបញ្ជីវិញ ហើយហេតុដូច្នេះ រារាំងអង្គការនោះ ពីការចុះបញ្ជីជានីតិបុគ្គល (សូមមើល មាត្រា ១៧ និង១៨)។*

*លើសពីនេះទៅទៀត ក្នុងសេចក្តីព្រាងច្បាប់លើកទីមួយ មានមាត្រា ១៨ ដែលផ្តល់ឲ្យមាននូវដំណើរដ៏មានកំរិតសំរាប់អាចប្តឹងតវ៉ាបាន ដើម្បីប្រើប្រាស់នៅក្នុងស្ថានការណ៍ ដែលសមាគម ឬ អង្គការមិនមែនរដ្ឋាភិបាល ខកខានក្នុងការបំពេញតាមលក្ខខ័ណ្ឌតម្រូវនៃការចុះបញ្ជី។ មាត្រា ១៨ ចាស់ ចែងថា ក្រសួងមហាផ្ទៃធ្វើលិខិតជូនដំណឹងជាលាយល័ក្ខអក្សរ ទៅឲ្យអ្នកដាក់ពាក្យអំពីខ្លឹមសារមិនទាន់សមស្របដែលមាននៅក្នុងសំណុំបែបបទរបស់ពួកគេ និងអនុញ្ញាតិឲ្យអ្នកដាក់ពាក្យសុំ ធ្វើការកែតម្រូវ ខ្លឹមសារមិនទាន់សមស្របនោះ ក្នុងរយៈពេល៤៥ថ្ងៃ ។ ដំណើរការសម្រាប់ធ្វើការប្តឹងតវ៉ាដ៏មានកំរិតនេះ ត្រូវបានដកចេញទាំងស្រុង ពីសេចក្តីព្រាងច្បាប់លើកទីពីរ។ នៅពេលដែលសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកត្រូវបានបដិសេធការចុះបញ្ជី ឬការចុះបញ្ជីឡើងវិញ សេចក្តីព្រាងច្បាប់លើកទីពីរ មិនបានផ្តល់ជាមធ្យោបាយក្នុងប្តឹងតវ៉ាចំពោះសេចក្តីសម្រេចនេះទេ។*

*តាមមាត្រា១៧ នាពេលនេះ គឺក្រសួងមហាផ្ទៃ មានពេលវេលា ៩០ថ្ងៃ នៃថ្ងៃធ្វើការ (នៅក្នុងសេចក្តីព្រាងលើកទីមួយ មានតែរយៈពេល ៤៥ថ្ងៃនៃថ្ងៃធ្វើការ) ដើម្បីពិនិត្យសំណុំលិខិត និងសម្រេចព្រមទទួល ចុះបញ្ជី និងចុះបញ្ជីឡើងវិញរបស់សមគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក។ ការកែប្រែ នេះអាចអនុញ្ញាតិឲ្យក្រសួងមហាផ្ទៃប្រើប្រាស់ការិយាធិបតេយ្យ ដើម្បីជាលេសក្នុងការមិនអនុញ្ញាតិឲ្យសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកថ្មីៗ មានប្រតិបត្តិការ ហើយនិងផ្អាកដល់កិច្ចប្រតិបត្តការ របស់សមាគមដែលមានស្រាប់ រហូតដល់១៨ សប្តាហ៍នៃថ្ងៃធ្វើការ*

*ក្នុងអំឡុងពេលដែលការចុះបញ្ជីកំពុងតែត្រូវបាន សម្រេចព្រមទទួល (ដែលវាមានរយៈពេលជិត ៦ខែ ប្រសិន បើគិតទាំងថ្ងៃឈប់សម្រាកផង)។ រយៈពេលដ៏យូរនេះកាន់តែ ជាបញ្ហាជាពិសេស ដោយសារការខ្វះដំណើរការប្តឹងតវ៉ា និងរឹតតែមានបញ្ហាបន្ថែមទៀត បើពិនិត្យ មាត្រា៥៥ ដែល បញ្ជាក់ថាសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដែលមានស្រាប់ ត្រូវតែដាក់ពាក្យសុំចុះបញ្ជីម្តង ទៀត ក្នុងរយៈពេល៣៦៥ ថ្ងៃនៃថ្ងៃធ្វើការចាប់ ពីពេលច្បាប់នេះចូលជាធរមាន (បានកែប្រែពី ១៨០ ថ្ងៃនៃថ្ងៃធ្វើការដែលបានកំណត់ក្នុងសេចក្តីព្រាងច្បាប់ទីលើកមួយ)។ សមាគម និងអង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុកមួយចំនួន អាចនឹងមិនមានលទ្ធភាពក្នុងការរៀបចំ បំពេញសំណុំបែបបទដែល ចាំបាច់ទាំងនេះភ្លាមៗបានទេ បន្ទាប់ពីច្បាប់នេះត្រូវបានប្រកាសឲ្យប្រើ។ ប្រសិនបើពួកគេរង់ចាំ ដល់ទៅរយៈពេល ៧ ឬ ៨ខែ ហើយនៅពេលដែលរយៈពេល ៣៦៥ថ្ងៃ ត្រូវផុតកំណត់នោះនឹងត្រូវ បានគិតថា ពាក្យសុំរបស់ពួកគេនឹងនៅកំពុងតែរង់ចាំការសម្រេចចុះបញ្ជីនៅឡើយ។ ដូច្នេះតើពួក គេអាចបន្តប្រតិបត្តិការការងារបានទេនៅខណៈពេលដែលការចុះបញ្ជី កំពុងតែស្ថិតក្នុងការរង់ចាំ សេចក្តីសម្រេច? ច្បាប់នេះមានន័យមិនច្បាស់លាស់លើចំនុចនេះ។ តើសមាគម និងអង្គការមិន មែនរដ្ឋាភិបាលក្នុងស្រុកដែលមានមូលដ្ឋាននៅតាមខេត្តនានា អាចនឹងមានលទ្ធភាព ចំណាយ ពេលវេលាចាំបាច់ដ៏ច្រើនក្រៃលែង នៅក្នុងទីក្រុងភ្នំពេញ ដើម្បីរៀបចំសំណុំបែបបទរបស់ពួកគេ និងធ្វើការជាមួយ ក្រសួងមហាផ្ទៃដើម្បីចុះបញ្ជី ឬចុះបញ្ជីសារជាថ្មី ដែរឬទេ?*

*នៅទីបញ្ចប់ រដ្ឋាភិបាលត្រូវតែធានាថា សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែល បង្កើតថ្មី ត្រូវបានអនុញ្ញាតិឲ្យប្រតិបត្តការ ក្នុងពេលដែលកំពុងតែរង់ចាំការយល់ព្រមចុះបញ្ជី ដូច ដែលរដ្ឋាភិបាលអនុញ្ញាតិឲ្យដល់ ក្រុមហ៊ុនឯកជននានា តាមមាត្រា ២៦ នៃច្បាប់ដែលបានកែប្រែ ឆ្នាំ១៩៩៩ ស្តីពីវិធានពាណិជ្ជកម្ម និងការចុះបញ្ជីពាណិជ្ជកម្ម។*

*មាត្រា ១៩ **ដល់ មាត្រា** ២៧ គ្រប់គ្រង ការចុះបញ្ជី សម្ព័ន្ធសមាគម និងអង្គការមិនមែន រដ្ឋាភិបាល។ នៅក្នុងសេចក្តីព្រាងច្បាប់លើកទីពីរ និយមន័យ "សម្ព័ន្ធ" ត្រូវបានប្តូរពីមាត្រា ៤ ទៅ ក្នុងមាត្រា១៩ វិញ និងឥឡូវនេះមានបញ្ចូលឃ្លាថា សម្ព័ន្ធសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ទាំងអស់ត្រូវតែចុះបញ្ជី។ សម្ព័ន្ធ នៅតែត្រូវបានកំណត់និយមន័យថា ជាសមាគម ឬអង្គការមិន មែនរដ្ឋាភិបាល ដែលបានរៀបចំចងក្រងគ្នាជាសម្ព័ន្ធក្នុងគោលបំណងរួមណាមួយដើម្បីបម្រើផល ប្រយោជន៍សាធារណៈ។ សេចក្តីព្រាងច្បាប់លើកទីមួយ បានបញ្ជាក់ថាសម្ព័ន្ធ អាចត្រូវបានរៀបចំ ចងក្រងឡើង តែរវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដូច្នេះ អង្គការមិនមែនរដ្ឋា ភិបាលអន្តរជាតិ ត្រូវបានផាត់ចេញពីការចូលរួមជាមួយនឹងសម្ព័ន្ធក្នុងស្រុក។ **មាត្រា ២១** នៃ សេចក្តីព្រាងច្បាប់លើកទីពីរ ឥឡូវនេះ អនុញ្ញាតិឲ្យអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិចូលរួម សម្ព័ន្ធជាមួយនឹងសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក តែទោះបីជាយ៉ាងណាក៏ដោយ*

*ក៏អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ មិនអាចដឹកនាំសម្ព័ន្ធបានទេ។*

***ការផ្ដល់អំណាចច្រើនហួសដល់មន្ត្រីរដ្ឋាភិបាលៈ*** ការផ្សំចូលគ្នានៃការដាក់កំហិតលើសេរីភាពខាងសមាគម និងល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការចុះបញ្ជីដោយច្បាប់នេះ គឺជាការប្រគល់នូវអំណាចដ៏ទូលំទូលាយ ដល់ក្រសួងនានារបស់រដ្ឋាភិបាលមានសមត្ថកិច្ចខាងការចុះបញ្ជី។ (ក្នុងករណីនៃសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសម្ព័ន្ធសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ការចុះបញ្ជីគឺជាសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ។ ចំពោះអង្គការមិនមែនរដ្ឋាភិបាលបរទេស គឺក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលត្រូវបានប្រគល់អំណាចឲ្យ ដើម្បីធ្វើសេចក្ដីសម្រេចលើសំណុំបែបបទចុះអនុស្សរណៈជាមួយរដ្ឋាភិបាល ដើម្បីប្រតិបត្តិការការងារក្នុងប្រទេសកម្ពុជា។) ដូចជាការកត់សំគាល់ពីមុនៗមក ច្បាប់មិនមានចែងអំពី សិទ្ធិប្ដឹងតវ៉ាចំពោះសេចក្ដីសម្រេចដែលធ្វើឡើងដោយក្រសួងទាំងនេះទេ ដែលអំណាចរបស់ក្រសួងទាំងនេះមានរួមទាំងការសម្រេចលើការចុះបញ្ជីនៃសំណុំបែបបទ និង ការបញ្ជាឲ្យមានការផ្អាកសកម្មភាពនៃអង្គការដែលបានចុះបញ្ជី[២២]។

អ្វីដែលជាការព្រួយបារម្ភបំផុតនោះ គឺច្បាប់នេះ ខ្វះខាតមូលដ្ឋានច្បាស់លាស់ ចំពោះការបដិសេធការចុះបញ្ជីសមាគម ឬអង្គការក្រៅរដ្ឋាភិបាល។ ហេតុនេះ មិនមានផ្ដល់ឲ្យមាននូវការការពារ ដើម្បីទប់ស្កាត់ការធ្វើសេចក្ដីសម្រេចដែលមានលក្ខណៈបំពានដោយក្រសួងទាំងនេះទេ។ សូម្បីតែសំណុំបែបបទមិនត្រូវបានបដិសេធទាំងស្រុងក៏ដោយ ក៏ល័ក្ខខ័ណ្ឌតម្រូវជាច្រើន សម្រាប់ការចុះបញ្ជីបានផ្ដល់ដល់មន្ត្រីនូវវិសាលភាពមួយក្នុងការសម្រេចថា សំណុំបែបបទមិនមានល័ក្ខ-ខ័ណ្ឌពេញលេញតាមការតម្រូវមួយនេះ ឬក៏មួយនោះ ដែលកើតទៅជារឿងពន្យាពេល ហើយដែលជាការគំរាមកំហែង និងធ្វើឲ្យពួកគេមានការរាំរែក ក្នុងការបន្តដំណើរការនៃសំណុំបែបបទរបស់ពួកគេ (ជាពិសេសចំពោះក្រុមដែលមានមូលដ្ឋាននៅតាមខេត្ត ដែលគ្មានមធ្យោបាយដើម្បីធ្វើដំណើរញឹកញាប់មករាជធានីភ្នំពេញ)។ មន្ត្រីអាចនឹងធ្វើរឿងនេះ មិនមែនតែសម្រាប់ហេតុផលនយោបាយ និងដើម្បីផាត់ចេញនូវអង្គការនានា ដែលមិនមែនជាការពេញចិត្តរបស់រដ្ឋាភិបាលប៉ុណ្ណោះទេ តែក៏ដើម្បីជំរិតទារប្រាក់សំណូកពីអ្នកដាក់សំណុំបែបបទផងដែរ[២៣]។

កង្វល់ជាពិសេសគឺថា ច្បាប់បានឲ្យអំណាចដល់ក្រសួងមហាផ្ទៃ ដើម្បីកំណត់លើបញ្ហាផ្លូវច្បាប់ និងធម្មនុញ្ញភាព ទាក់ទងនឹងសំណុំបែបបទសុំចុះបញ្ជីរបស់អង្គការ[២៤]។ ចំណុចនេះ គឺបើកផ្លូវឲ្យមានការរំលោភ និងផ្ដល់នូវអំណាចខាងពិនិត្យនីត្យានុកូល ទៅដល់ក្រសួងមហាផ្ទៃ ដែលវាមិនសមស្របទាល់តែសោះសម្រាប់រដ្ឋដែលអះអាងពីការគោរព ការបែងចែកអំណាចទាំងបីដាច់ដោយឡែកពីគ្នា។

ក្រៅតែពី មិនបានផ្ដល់ឲ្យតុលាការ ដើម្បីត្រួតពិនិត្យតាមផ្លូវតុលាការលើការចុះបញ្ជីច្បាប់

នេះក៏និយាយបែបព្រាលៗដល់តុលាការថា អាចបង្ខំឲ្យផ្អាក ឬរំលាយ អង្គការក្នុងស្រុក និងអង្គការបរទេស (និងបានកំណត់ពីអ្វីដែលនឹងកើតឡើងចំពោះទ្រព្យសម្បត្តិរបស់អង្គការ)[២៥]។ វាមិនបានចែងអំពីមូលដ្ឋានអ្វីដែលផ្តល់ឲ្យមានចំណាត់ការនេះទេ។ ភាពមិនច្បាស់លាស់នេះ លើកឡើងនូវគ្រោះថ្នាក់យ៉ាងពិតប្រាកដ ដែលបទប្បញ្ញត្តិនេះអាចត្រូវបានប្រើប្រាស់ដើម្បីបិទអង្គការ ពេលមានសំណើរទៅតុលាការពីរដ្ឋាភិបាល ក្រោមលេសថាអង្គការបានប្រព្រឹត្តអំពើមិនត្រឹមត្រូវ។[២៦]

ការព្រួយបារម្ភចំពោះហេតុផលដូចគ្នានេះដែរ គឺប្រយោគមួយទៀត ដែលផ្តល់ឲ្យក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អាចចាត់វិធានការតាម "ច្បាប់ជាធរមាន" ចំពោះអង្គការក្រៅរដ្ឋាភិបាល ដែលត្រូវបានពិចារណាថា អនុវត្តមិនត្រឹមត្រូវតាមលក្ខន្តិកៈ ឬអនុស្សរណៈជាមួយរដ្ឋាភិបាល[២៧]។ វាក៏មិនច្បាស់លាស់ថាតើវាយោងច្បាប់មួយណាទេ ឬក៏ថាអ្វីទៅ ដែលបង្កើតបានជាការប្រព្រឹត្តិល្មើសនឹងលក្ខន្តិកៈ ឬអនុស្សរណៈ។ ដោយសារតែទំហំនៃព័ត៌មាន ដែលតម្រូវឲ្យមានសម្រាប់លក្ខន្តិកៈរបស់អង្គការ វាមានគ្រោះថ្នាក់ចំពោះបញ្ហាខុសឆ្គងបន្តិចបន្តួច កើតចេញពីលក្ខន្តិកៈ ដែលអាចត្រូវបានប្រើប្រាស់ដោយរដ្ឋាភិបាលដើម្បីចាត់វិធានការតាមផ្លូវច្បាប់ ផ្អាក ឬបិទអង្គការ។

## ►►►សេចក្តីអត្ថាធិប្បាយលើពង្រាងច្បាប់លើកទីពីរ

*សេចក្តីព្រាងច្បាប់លើកទីពីរ មិនបានឆ្លើយតបចំពោះកង្វល់ខាងលើទេ។*

*ជាអាទិ៍ **មាត្រា ១៣** ដែលកំណត់ពី ថ្លៃអាករ ចុះបញ្ជី ក្រុមអង្គការសង្គមស៊ីវិល ដែលនៅតែមានស្រពិចស្រពិល។ មាត្រានេះគ្រាន់តែចែងថា ថ្លៃអាករចុះបញ្ជី "ត្រូវកំណត់ដោយ ប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។" ថ្លៃអាករចុះបញ្ជីគឺជាផ្នែកមួយយ៉ាងសំខាន់នៃច្បាប់នេះ ហើយគួរតែត្រូវបានយកមកពិភាក្សាជាសាធារណៈ ដើម្បីធានាថា ទម្រង់ថ្លៃអាករ ឆ្លុះបញ្ចាំងនូវស្ថានភាពរបស់ក្រុមអង្គការសង្គមស៊ីវិលដែលជាស្ថាប័នមិនរកផលកម្រៃ។ លើសពីនេះទៅទៀត ក្រុមអង្គការសង្គមស៊ីវិលជាច្រើន មានថវិការតិចតួច ដូច្នេះការកំណត់ ថ្លៃអាករខ្ពស់ អាចនឹងធ្វើឲ្យប៉ះពាល់យ៉ាងពិតប្រាកដដល់ប្រតិបត្តការរបស់ពួកគេ។*

*យ៉ាងហោចណាស់ ច្បាប់នេះគួរតែមានគោលការណ៍ណែនាំច្បាស់លាស់ពីរបៀប ដែលថ្លៃអាករ នឹងត្រូវកំណត់ឡើង ដើម្បីទប់ស្កាត់ការរំលោភឆន្ទានុសិទ្ធិដោយមន្ត្រីនៃផ្នែកនីតិប្រតិបត្តិ ដែលជាអ្នកធ្វើការកំណត់ អំពីថ្លៃអាករ នៅពេលក្រោយ។*

***ល័ក្ខខ័ណ្ឌតម្រូវឲ្យផ្ញើរបាយការណ៍ជាការបំពាន:*** ច្បាប់ដាក់ការទាមទារជាកំហិតដ៏ជ្រុលហួសហេតុលើអង្គការក្រៅរដ្ឋាភិបាល និងសមាគម ឲ្យផ្ញើរបាយការណ៍ជូនរដ្ឋាភិបាល។ ក៏តម្រូវឲ្យ

ដាក់ជូនរបាយការណ៍ប្រចាំឆ្នាំទៅក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងមានរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ឲ្យក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអជ្ញាធរសវនកម្មជាតិត្រួតពិនិត្យ និងអង្គការមិនមែនរដ្ឋាភិបាល សមាគមក្នុងស្រុក ឬអង្គការក្រៅរដ្ឋាភិបាលបរទេសត្រូវតែជូនដំណឹងដល់រដ្ឋាភិបាល នៅរៀងរាល់ពេលដែលមានការប្តូរឈ្មោះ ការធ្វើវិសោធនកម្មលក្ខន្តិកៈ ការផ្លាស់ប្តូរទីស្នាក់ការ ឬការផ្លាស់ប្តូរ ឬបញ្ឈប់បុគ្គលិក សមាជិក ឬមេដឹកនាំ[២៨]។ អង្គការ សមាគម ត្រូវតែជូនដំណឹងដល់អាជ្ញាធរក្រុង ឬខេត្ត បើសិនជាមានបើកសាខាស្នាក់ការ "ឬធ្វើសកម្មភាព" ក្នុងរាជធានីភ្នំពេញ ឬតាមខេត្ត[២៩]។ (ចំនុចនេះជាការបើកផ្លូវមួយឲ្យមានការតម្រូវឲ្យអង្គការ សមាគម រាយការណ៍ទៅអាជ្ញាធរមូលដ្ឋាន រាល់លើក និងរាល់ពេល ដែលពួកគេទៅកាន់ទីកន្លែង ណាមួយដើម្បីធ្វើសកម្មភាពណាមួយ។)

## ►►► សេចក្តីអត្ថាធិប្បាយលើពង្រាងច្បាប់ លើក**ទីពីរ**

*ការផ្លាស់ប្តូរជាអវិជ្ជមានមួយនោះគឺថា **មាត្រា ៤៤** នៃពង្រាងច្បាប់លើកទីពីរ លែងបញ្ជាក់ពីភាពចាំបាច់សម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការជូនដំណឹងទៅក្រសួងមហាផ្ទៃ នៅពេលផ្លាស់ប្តូរ បញ្ចប់ ឬបញ្ឈប់បុគ្គលិកទេ។ ទោះបីជាយ៉ាងណាក៏ដោយ វានៅតែចែងថា ក្រសួងមហាផ្ទៃត្រូវតែទទួលបានការជូនដំណឹងជាលាយលក្ខអក្សរ ប្រសិនបើមានការផ្លាស់ប្តូរប្រធាន ឬថ្នាក់ដឹកនាំ អង្គការ។*

*តម្រូវការនៃការផ្តល់របាយការណ៍ទាំងអស់មានកំណត់ក្នុង**មាត្រា ៤៦** នៅដដែល រួមទាំងកាតព្វកិច្ចដាក់ជូនរបាយការណ៍ស្តីពីសកម្មភាពប្រចាំឆ្នាំ ស្ថានភាពថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំដែលបានគ្រោងទុក ទៅកាន់ក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងកិច្ចសហប្រតិបត្តិការអន្តរជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងពាក់ព័ន្ធនានា នៅដំណាច់ខែកុម្ភៈ។*

*ការកែប្រែនៅក្នុង**មាត្រា៤៨** ជាមាត្រាដែលនិយាយសំដៅទៅលើសិទ្ធិរបស់ក្រសួងហិរញ្ញវត្ថុក្នុងការត្រួតពិនិត្យរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ បានធ្វើឲ្យវិសាលភាពនៃមាត្រានេះមិនច្បាស់លាស់។ មាត្រានេះចែងថា ក្រសួងអាចត្រួតពិនិត្យរបាយការណ៍ស្តីពី ស្ថានភាពហិរញ្ញវត្ថុរបស់ "សមាគម និងអង្គការមិនមែនរដ្ឋាភិបាលដូចមានចែងក្នុងមាត្រា ១០ ជំពូក ២ នៃច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា"។ ប៉ុន្តែមាត្រា១០ ក្នុងច្បាប់សវនកម្ម បានចែងថា វាអនុវត្តបានតែចំពោះសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលទទួលបាន "ជំនួយហិរញ្ញវត្ថុពីរដ្ឋាភិបាល នៅក្នុងទម្រង់នៃការអនុញ្ញាតិឲ្យរួចពីកាតព្វកិច្ចពន្ធគយ ពន្ធលើប្រាក់ចំណូល និងទម្រង់ពន្ធ ប្រភេទផ្សេងទៀត ព្រមទាំងសិទ្ធិនិងផលប្រយោជន៍ផ្សេងៗ មិនត្រូវបានផ្តល់ ឲ្យដោយ*

*ច្បាប់។*

***មាត្រា៤២ នៃ****ច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលចែងថា ក្រុមអង្គការសង្គមស៊ីវិលអាច "ស្នើសុំនាំចូលសម្ភារៈ គ្រឿងបរិក្ខារចាំបាច់សម្រាប់ប្រើប្រាស់ស្របតាមគម្រោង និងកម្មវិធីការងាររបស់ខ្លួន ដោយពន្ធ និងអាករលើការនាំចូល ជាបន្ទុករបស់រដ្ឋ និងតាមការសម្រេចរបស់រាជរដ្ឋាភិបាល"។ ពន្ធនិងអាករ វៀបរាប់បំបែក ក្នុងមាត្រា ៤២ នឹងត្រូវ ផ្តល់ឲ្យតាមឆន្ទានុសិទ្ធិរបស់រាជរដ្ឋាភិបាល នោះវាស្តែងឲ្យឃើញថា ខចែងអំពីសវនកម្មនៃ មាត្រា ៤៨ ត្រូវអនុវត្តបានតែនៅពេលណាដែលអង្គការសង្គមស៊ីវិលណាមួយ ទទួលបានផលប្រយោជន៍បែបនេះប៉ុណ្ណោះ។ ប៉ុន្តែ ភាសានៅក្នុងមាត្រា៤៨ មានលក្ខណៈដាច់ខាត ដោយបញ្ជាក់ថា ក្រុមអង្គការសង្គមស៊ីវិលទាំងអស់នឹងត្រូវបានធ្វើសវនកម្ម។ រាជរដ្ឋាភិបាល គួរតែបញ្ជាក់ឲ្យច្បាស់នៅក្នុង មាត្រា ៤៨ ដើម្បីឲ្យមាត្រានេះស្របនឹងច្បាប់ស្តីពីសវនកម្ម។*

***ការដាក់កំហិតលើអង្គការក្រៅរដ្ឋាភិបាលបរទេស:*** អង្គការក្រៅរដ្ឋាភិបាលបរទេសប្រឈមនឹងការដាក់កំហិតនានាក្រោមច្បាប់នេះ រួមមានការតម្រូវឲ្យពួកគេត្រូវតែមានការគាំទ្រពី (និងមានកិច្ចព្រមព្រាងជាមួយ) ស្ថាប័នរដ្ឋាភិបាល មុននឹងដាក់ពាក្យសុំចុះអនុស្សរណៈជាមួយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ សហការជាចាំបាច់ជាមួយរដ្ឋាភិបាល គឺជាការតម្រូវសម្រាប់អង្គការក្រៅរដ្ឋាភិបាលបរទេសដែល "ត្រូវសហការជាមួយក្រសួង ឬស្ថាប័នរបស់ [រាជរដ្ឋាភិបាល] នៅពេលរៀបចំផែនការគម្រោង អនុវត្ត ត្រួតពិនិត្យ និងការបូកសរុប និងវាយតម្លៃលទ្ធផលសកម្មភាព ដែលបានអនុវត្តរួចហើយ"។ អង្គការក្រៅរដ្ឋាភិបាលបរទេស ក៏តម្រូវឲ្យមាន និងបន្តសុពលភាពនៃអនុស្សរណៈជាមួយរដ្ឋាភិបាលរៀងរាល់មួយទៅបីឆ្នាំ ដែលប្រសិទ្ធិភាពរបស់វា គឺមានតាមរយៈការចុះអនុស្សរណៈឡើងវិញជាទៀងទាត់[៣០]។ បទប្បញ្ញត្តិទាំងនេះទំនងជានឹងនាំឲ្យមាននយោបាយកម្មយ៉ាងសម្បើមលើជំនួយបរទេស ហើយអង្គការមិនមែនរដ្ឋាភិបាលបរទេសមួយចំនួន - ដូចជាអង្គការទាំងឡាយណាដែលមានបំណងធ្វើការជាចម្បងជាមួយដៃគូសង្គមស៊ីវិលក្នុងស្រុក ជាជាងជាមួយរដ្ឋាភិបាល ដើម្បីលើកកំពស់សមត្ថភាពពួកគេ - អាចនឹងត្រូវបដិសេធការអនុញ្ញាតិលើកិច្ចប្រតិបត្តិការរបស់ខ្លួន។ ដូចដែលអ្នកជំនាញការអន្តរជាតិមួយក្រុមខាងច្បាប់មិនរកផលចំណេញ ធ្វើអត្ថាធិប្បាយថា "ការចុះបញ្ជីអង្គការក្រៅរដ្ឋាភិបាលបរទេសអាចរួមរឹតទៅដោយការពន្យាពេល និងក្រោមការធ្វើសេចក្តីសម្រេចចិត្តទៅតាមគំនិតនៃជនណាម្នាក់ដោយបំពាន និងមានលក្ខណៈនយោបាយ"[៣១]។

## ►►► សេចក្តីអត្ថាធិប្បាយលើពង្រាងច្បាប់លើកទីពីរ

***មាត្រា ៣៣*** *ត្រូវបានកែប្រែ ដែលតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិត្រឹមតែ*

*"ធ្វើការពិភាក្សាឯកភាព" ជាមួយក្រសួងដែលជាដៃគូរ ជាជាងការចុះកិច្ចព្រមព្រៀងលើគម្រោង ឬកម្មវិធីជំនួយនានា" និងលែងចែងច្បាស់ថា ការពិភាក្សាទាំងនេះ ត្រូវតែធ្វើឡើង ជាមួយនឹងថ្នាក់ដឹកនាំរបស់ក្រសួង។*

*ការតម្រូវឲ្យផ្តល់របាយការណ៍ សម្រាប់កិច្ចសហប្រតិបត្តិការរវាង អង្គការមិនមែនរដ្ឋាភិបាលបរទេស និងក្រសួង ឬជាមួយអាជ្ញាធរដទៃទៀត មានភាពម៉ឹងម៉ាត់តិចតួច។ អង្គការមិនមែនរដ្ឋាភិបាលបរទេស ឥឡូវនេះត្រូវជូនដំណឹងតែក្រសួង ឬស្ថាប័នរដ្ឋាភិបាល ដែលជាដៃគូរ ប្រសិនបើពួកគេអនុវត្តគម្រោង ឬកម្មវិធីជំនួយ ជាជាងការជូនដំណឹងផងដែរទៅដល់សាលាក្រុង ឬសាលាខេត្តពាក់ព័ន្ធ។*

## ៤- បទដ្ឋានអន្តរជាតិ

សេចក្តីព្រាងច្បាប់មិនស្របតាមបទដ្ឋានអន្តរជាតិទេ។ ចំពោះចំណុចពិស្តារអ្វីខ្លះនៃបញ្ញត្តិនានា របស់ច្បាប់នេះដែលរំលោភបទដ្ឋានអន្តរជាតិ សូមមើលយោបល់ លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល របស់ព្រះរាជាណាចក្រកម្ពុជា ដោយមជ្ឈមណ្ឌលអន្តរជាតិសំរាប់ច្បាប់មិនរកផលចំណេញ (ICNL) ដែលបានធ្វើការងារលើគម្រោងកំនែទម្រង់ច្បាប់សង្គមស៊ីវិលនៅក្នុងប្រទេសច្រើនជាង១០០។ ជាពិសេស សេចក្តីព្រាងច្បាប់ខកខានមិនគោរពតាមបទប្បញ្ញត្តិស្តីពី សេរីភាពខាងសមាគម ដែលមានចែងក្នុងកាតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័ន។

តាមការពិតជាក់ស្តែង សេចក្តីព្រាងច្បាប់នេះមានទៅដោយសញ្ញាសំគាល់ជាច្រើន ថាជាច្បាប់គាបសង្កត់លើអង្គការក្រៅរដ្ឋាភិបាល ដែលច្បាប់ប្រភេទនេះត្រូវបានប្រើប្រាស់ដោយ របបមិនប្រជាធិបតេយ្យ នៅជុំវិញពិភពលោក ដើម្បីត្រួតត្រាសង្គមស៊ីវិល។ ក្នុងឆ្នាំ២០០៤ តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិខាងអ្នកការពារសិទ្ធិមនុស្ស លោកស្រី ហ៊ីណា ជីឡានី បានលើកយកមកបង្ហាញនូវបញ្ហាជាទូទៅនៃច្បាប់ដែលមានលក្ខណៈគាបសង្កត់របៀបនេះ ដែលរួមមាន:

- និតិវិធីចុះបញ្ជីមានលក្ខណៈស្មុគ្រស្មាញដែលមិនជាការចាំបាច់ និងមានរយៈពេលវែង
- ដាក់កំហិតលើការបង្កើតបណ្តាញ
- ការបដិសេធការចុះបញ្ជីដោយមិនសមស្រប
- ឯករាជ្យភាពមានដែនកំណត់នៃអជ្ញាធរខាងការចុះបញ្ជី
- រដ្ឋពិនិត្យពិច័យលើ និងជ្រៀតជ្រែកចូលក្នុង ការងារគ្រប់គ្រង ទិសដៅ និងសកម្មភាពរបស់

អង្គការ

- យាយីតាមផ្លូវរដ្ឋបាល និងផ្លូវតុលាការ[៣២]។

បញ្ហាទាំងអស់នេះ និងវិធានការគាបសង្កត់ដទៃទៀត អាចនឹងចេញជាលទ្ធផលពីការអនុម័តលើសេចក្តីព្រាងច្បាប់អង្គការក្រៅរដ្ឋាភិបាលនេះ នៅកម្ពុជា។ ហើយវានឹងមានសភាពខ្លាំងថែមទៀត ដោយសារថាប្រទេសនេះមាននូវកត្តាទាំងអស់ ដែលតំណាងពិសេសនៃអគ្គលេខាធិការអង្គការ សហប្រជាជាតិបានលើកឡើងថាជាកត្តា ដែលអនុញ្ញាតិឲ្យកើតមានឡើងនូវអំពើហិង្សាលើអ្នកការពារសិទ្ធិមនុស្ស៖

- ភាពខ្សោយរបស់ច្បាប់ និងរបស់នីតិវិធីខាងផ្លូវច្បាប់
- សមត្ថភាព និងឯករាជ្យភាពរបស់តុលាការ នៅមានកំរិត
- ខ្វះខាតសម្បជញ្ញៈ ឬការទទួលខុសត្រូវ ក្នុងចំនោមអាជ្ញាធរមូលដ្ឋាន ចំពោះការគោរពបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ និង
- ភាពខ្សោយ ក្នុងចំនោមសង្គមស៊ីវិល។

## ៥- សេចក្តីសន្និដ្ឋាន និងអនុសាសន៍ចុងក្រោយ

សេចក្តីព្រាងច្បាប់នេះស្វះស្វែងដើម្បីដកយកអក្សរ [ក្នុងន័យជាភាសាអង់គ្លេស] "N" ចេញពី "NGOs" ឬ [ក្នុងន័យជាភាសាខ្មែរ] "មិនមែន" ចេញពី "អង្គការមិនមែនរដ្ឋាភិបាល" ដែលនឹងធ្វើឲ្យអង្គការមិនមែនរដ្ឋាភិបាលនានា [NGOs] ក្លាយទៅជាអង្គការរដ្ឋាភិបាលយ៉ាងប្រសិទ្ធិភាព។ សេចក្តីព្រាងច្បាប់ទីពីរនេះមានកំហុសដដែលៗ។ ច្បាប់នេះ បានមើលរំលង លើគ្រប់គោលគំនិតស្តីពី អង្គការមិនមែនរដ្ឋាភិបាល សមាគម និងតួអង្គសង្គមស៊ីវិលដទៃទៀត ជាគំនិតដែលថាពួកគេធ្វើការងារដោយឯករាជ្យ និងមិនគួរត្រូវបានត្រួតត្រាដោយរដ្ឋាភិបាល ថា ពួកគេមិនអាចត្រូវបានបង្ខិតបង្ខំឲ្យសហការជាមួយរដ្ឋាភិបាល (ជាជាងដោយការជ្រើសរើស) និងថាពួកគេគួរតែត្រូវបានការពារពីការយាយី និងការដាក់កំហិតដោយរំលោភបំពាន លើ សកម្មភាពស្របច្បាប់របស់ខ្លួន។

វាជាភស្តុតាងបង្ហាញថា ច្បាប់នេះមានគោលបំណងដើម្បីបង្កើតជាឧបសគ្គដល់ការចុះបញ្ជីសមាគម និងអង្គការក្រៅរដ្ឋាភិបាល ធ្វើឲ្យពួកគេចំណាយពេលវេលា និងធនធានច្រើនក្នុងដំណើរការមួយដ៏ស្មុគ្រស្មាញ ហើយដែលបើកផ្លូវឲ្យមន្ត្រីរដ្ឋាភិបាល ធ្វើសេចក្តីសម្រេចតាមទំនើងចិត្ត និងគ្មានតម្លាភាព ជាជាងការពង្រឹងដល់សង្គមស៊ីវិល។ សេចក្តីព្រាងច្បាប់លើកទីពីរនេះមិនដោះ

ស្រាយបញ្ហានេះទេ ហើយវាអាចនឹងធ្វើឲ្យបញ្ហាកាន់តែអាក្រក់ទៅៗ។

តាមរយៈការស្វែងរកការដាក់កំហិតលើសេរីភាពខាងសមាគម និងដាក់បញ្ហាឲ្យក្រុមសង្គមស៊ីវិល ទទួលខុសត្រូវចំពោះមុខរដ្ឋាភិបាល ជាជាងចំពោះប្រជាពលរដ្ឋដែលពួកគេមានភារកិច្ចធ្វើការបំរើ ច្បាប់នេះនឹងធ្វើឲ្យសហគមនានារបស់កម្ពុជា កាន់តែស្ថិតនៅដាច់ឆ្ងាយ និងគ្មានអំណាច។ វានឹងធ្វើឲ្យអ្នកទាំងឡាយណាដែលកំពុងតែធ្វើការនៅកំរិតមូលដ្ឋានមានការប្រឈមចំពោះរបាំងការិយាធិបតេយ្យ និងមានគ្រោះថ្នាក់ជាខ្លាំងពីការយាយី ការគំរាមកំហែង ឬអំពើអាក្រក់ជាងនេះមានដូចជា អ្នកដែលត្រូវបានចាត់ថា ចេញមុខជាងគេក្នុងការអភិវឌ្ឍសហគម។

គួរត្រូវចងចាំថា សេរីភាពខាងសមាគម ការបញ្ចេញមតិ និងការប្រមូលផ្តុំ ក្នុងប្រទេសកម្ពុជា ត្រូវបានដាក់កំហិតជាខ្លាំងរួចទៅហើយ ជាពិសេសនៅឯកំរិតសហគម។ អ្នកភូមិមានសំលេងពិត ប្រាកដដ៏តិចតួចបំផុតលើ បញ្ហាដែលប៉ះពាល់សុខមាលភាព និងការអភិវឌ្ឍន៍របស់ខ្លួន ហើយអង្គការមិនមែនរដ្ឋាភិបាល និងក្រុមដទៃទៀតដែលស្វះស្វែងធ្វើការងារជាមួយអ្នកភូមិលើបញ្ហាទាំងនេះ ក៏មានសល់ផ្លូវតិចតួចដើម្បីធ្វើការងារដែរ។ នរណាម្នាក់ដែលគេអាចដឹងបានថាជាអ្នកបង្កបញ្ហាដល់មន្រ្តីមូលដ្ឋាន ឬមន្រ្តីរដ្ឋាភិបាល នឹងត្រូវប្រឈមនឹងការធ្វើទុក្ខបុកម្នេញ ដែលរួមមានការចាប់ខ្លួន និងការឃុំខ្លួន ឬការបំភិតបំភ័យ និងអំពើហិង្សា។ សេចក្តីព្រាងច្បាប់ត្រូវតែបានពិនិត្យ វាយតម្លៃ ក្នុងបរិបទនេះ។

# អនុសាសន៍

- រដ្ឋាភិបាលគួរតែធានាថាការចុះបញ្ជីណាមួយរបស់ក្រុមអង្គការសង្គមស៊ីវិល(ក្រោមច្បាប់នេះឬច្បាប់ផ្សេងទៀត) គឺជាការស្ម័គ្រចិត្ត និងមិនមែនជាការដាក់កំហិត។ ការចុះបញ្ជីដោយស្ម័គ្រចិត្តគឺជាលក្ខខ័ណ្ឌចាំបាច់ក្នុងការធានាថា ច្បាប់នេះគោរពដល់ សិទ្ធិមានសេរីភាពក្នុងការបង្កើតសមាគម ការប្រមូលផ្តុំ និងការបញ្ចេញមតិ របស់ប្រជាពលរដ្ឋខ្មែរ ក្រោមរដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញាអន្តរជាតិ។
- នៅខណៈពេលដែលច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាល ត្រូវបានអនុម័ត រាជរដ្ឋាភិបាលគួរតែទប់ចិត្តបញ្ឈប់ការចាប់ខ្លួន ការចាប់ដាក់ពន្ធនាគារ និងការកាត់ទោសព្រហ្មទណ្ឌ លើតំណាងសហគមន៍ និងប្រជាពលរដ្ឋដទៃទៀតដែលប្រើប្រាស់សិទ្ធិរបស់ពួកគាត់ស្របច្បាប់ ក្នុងការបញ្ចេញមតិដោយសេរី ការបង្កើតសមាគម ឬការប្រមូលផ្តុំ បើទោះបីមិនបានចុះបញ្ជី យោងទៅតាមច្បាប់ក៏ដោយ។
- ដោយយោងទៅតាមការចេញផ្សាយសេចក្តីព្រាងច្បាប់លើកទីមួយ រដ្ឋាភិបាលបានរៀបចំកិច្ច

ប្រជុំពិគ្រោះយោបល់ជាមួយនឹងសង្គមស៊ីវិល។ ការចេញផ្សាយសេចក្តីព្រាងច្បាប់លើកទីពីរ បង្ហាញឲ្យឃើញថាកិច្ចប្រជុំពិគ្រោះយោបល់ទាំងនោះមិនមានផលប្រយោជន៍ទាល់តែសោះ។ រដ្ឋាភិបាលទំនងជា "ធ្វើពុត" បង្ហាញពីកិច្ចសហប្រតិបត្តិការ និងការចូលរួម ដែលមានមើលឃើញតែពីខាងក្រៅ។ ដើម្បីផលប្រយោជន៍នៃការចូលរួមឲ្យប្រកបដោយតម្លាភាព និងបែបលទ្ធិប្រជាធិបតេយ្យ រាជរដ្ឋាភិបាលគួរតែរៀបចំនូវកិច្ចប្រជុំពិគ្រោះយោបល់ ប្រកបដោយអត្ថន័យ នៅថ្នាក់ខេត្ត និងថ្នាក់ជាតិ លើសេចក្តីព្រាងច្បាប់នេះ រួមទាំងពិនិត្យមើលថា តើច្បាប់បែបនេះ ជាការចាំបាច់ដែរឬទេ ហើយបើជាការចាំបាច់មែន តើមានការការពារអ្វីខ្លះ និងផលប្រយោជន៍អ្វីខ្លះ ដែលច្បាប់ត្រូវថែងសម្រាប់អង្គការដែលធ្វើការងារ ដើម្បីផលប្រយោជន៍សាធារណៈ។

- មុនពេល មានកិច្ចប្រជុំពិគ្រោះយោបល់នាពេលអនាគត រដ្ឋាភិបាលគួរតែ បញ្ជាក់ឲ្យបានច្បាស់ពីតម្រូវការក្នុងការមានច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដោយឡែកដោយហេតុថា ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ដែលនៅកំពុងតែរង់ចាំការប្រកាសឲ្យប្រើ មានផ្តល់ឲ្យនូវការចុះបញ្ជីដោយស្ម័គ្រចិត្ត ព្រមទាំងផ្តល់ឲ្យមាននូវបទប្បញ្ញត្តិគ្រប់គ្រាន់ ចំពោះគ្រប់អង្គការឬស្ថាប័ននិតិបុគ្គលស្របច្បាប់ទាំងអស់ - ទាំងចំពោះអង្គការមិនរកកម្រៃ និងអង្គការរកកម្រៃ។ មកទល់ពេលនេះ ហេតុផល ចម្បងតែមួយគត់របស់រាជរដ្ឋាភិបាលសម្រាប់ការមានច្បាប់នេះគឺផ្តើមចេញពីការព្រួយបារម្ភចំពោះចំនួនច្រើននៃក្រុមអង្គការមិនមែនរដ្ឋាភិបាល នៅក្នុងប្រទេសកម្ពុជា និងការប្រកាសអះអាងថាដើម្បីទប់ស្កាត់អំពើភេរវកម្ម។ ការបង្ហាញ ពីគោលបំណងច្បាស់លាស់នោះ នឹងអនុញ្ញាតឲ្យសាធារណៈជនវាយតម្លៃបាន ថាតើមាត្រានីមួយៗនៃច្បាប់នេះពិតជាបម្រើដល់ផលប្រយោជន៍សាធារណៈ ស្របច្បាប់នៅទីបំផុត។

---

[១] សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលៈ សង្គមស៊ីវិលកម្ពុជាស្ថិតក្រោមការគំរាមកំហែង របាយការណ៍សង្ខេបលីកាដូ ខែធ្នូ ឆ្នាំ២០១០ អាចចូលមើល http://www.licadho-cambodia.org/reports.php?perm=150&pagenb=&filter=-1)

[២] សូមមើល ឧទាហរណ៍ ប្រាក់ ចាន់ថុល "ប្រទេសកម្ពុជារងការរិៈគន់*លើការប៉ុនប៉ងមានច្បាប់*អង្គការមិនមែនរដ្ឋាភិបាល" រ៉ូទ័រ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១១

[៣] លោកថូម៉ាស មីល័រ "ការជជែកពីច្បាប់ស្តីពីអង្គការមិនមែនរដ្ឋាភិបាលមិនទាន់*បញ្ចប់ៈ* សហរដ្ឋអាមេរិក" កាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១

[៤] ការពិគ្រោះយោបល់" រួមមានៈ នៅថ្ងៃទី១០ ខែមករា -ពិគ្រោះយោបល់ថ្នាក់ជាតិនៅសណ្ឋាគារ កាំបូឌីយ៉ាណា។ នៅថ្ងៃទី២១ ខែមករា កិច្ចប្រជុំរវាងតំណាងក្រសួងមហាផ្ទៃ និងតំណាងអង្គការមិនមែនរដ្ឋាភិបាលនៅការិយាល័យក្រសួងមហាផ្ទៃ។ នៅថ្ងៃទី២៣ ខែកុម្ភៈ កិច្ចប្រជុំមួយព្រឹក រវាងតំណាងអង្គការមិនមែនរដ្ឋាភិបាលជប៉ុន និងតំណាងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តការអន្តរជាតិ និងនាពេលរសៀល មានកិច្ចប្រជុំរវាងតំណាងអង្គការមិនមែនរដ្ឋាភិបាល និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តការអន្តរជាតិ។ នៅថ្ងៃទី២៩ ខែមីនា កិច្ចប្រជុំរវាងតំណាងអង្គការសង្គមស៊ីវិល និងក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងកិច្ចសហប្រតិបត្តការអន្តរជាតិ នៅការិយាល័យក្រសួងមហាផ្ទៃ។

[៥] របាយការណ៍សង្ខេបនេះ ផ្អែកលើច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (សេចក្តីព្រាងដំបូង) ដែលបានចេញផ្សព្វផ្សាយដោយក្រសួងមហាផ្ទៃ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១០។

[៦] មាត្រា ១៦-១៩ នៃសេចក្តីព្រាងច្បាប់។

[៧] មាត្រា ៥៣។

[៨] មាត្រា៥៤។

[៩] មាត្រា៤៩-៥០ និងមាត្រា ៥២។

[១០] ក្រសួងមហាផ្ទៃ ក្រោយមកបានយល់ព្រមពន្យាពេលនៃ "ការពិគ្រោះយោបល់ថ្នាក់ជាតិ" ពីថ្ងៃទី២៨ ខែធ្នូ ទៅធ្វើនៅ ថ្ងៃទី១០ ខែមករា ឆ្នាំ២០១១ វិញដែលការពន្យាពេលនេះនៅតែក្នុងក្របខណ្ឌរយៈពេលខ្លីសម្រាប់សង្គមស៊ីវិលធ្វើការពិនិត្យ និងរៀបចំយោបល់ ចំពោះច្បាប់។

[១១] មជ្ឈមណ្ឌលអន្តរជាតិសំរាប់ច្បាប់មិនរកផលចំណេញ (ICNL) យោបល់លើសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល របស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ទំព័រ៧។ ICNL ក៏បានដកស្រង់យោបល់ របស់តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស លោកស្រី ហ៊ីណា ជីឡានី ដែលថ្លែងថា "ការចុះបញ្ជីមិនគួរជាកាតព្វកិច្ចទេ។ អង្គការមិនមែនរដ្ឋាភិបាលគួរតែបានអនុញ្ញាតឲ្យមាន និងធ្វើសកម្មភាព ដោយមិនចាំបាច់មានការចុះបញ្ជី បើសិនជាពួកគេមិនចង់ចុះបញ្ជីទេ។"

[១២] មាត្រា ៨ និងមាត្រា ៩។

[១៣] ច្បាប់ស្តីពីវិធាន និងការចុះបញ្ជីពាណិជ្ជកម្ម ឆ្នាំ១៩៩៥ (មាត្រា ១៧) និងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ឆ្នាំ២០០៥ (មាត្រា ៨៦)។

[១៤] មាត្រា ១៧ នៃសេចក្តីព្រាងច្បាប់ ចែងថា ក្រសួងមហាផ្ទៃមានរយៈពេលយ៉ាងយូរ ៤៥ថ្ងៃ នៃថ្ងៃធ្វើការ ដើម្បីសំរេច យល់ព្រម ឬមិនយល់ព្រមចុះបញ្ជីសមាគម ឬអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក។ បើយល់ឃើញថាសំណុំបែបបទ "មិនស្របតាមរដ្ឋធម្មនុញ្ញ ឬច្បាប់នានាជាធរមាន" អាចបញ្ជូនទៅវិញ និងសុំឲ្យធ្វើការកែតម្រូវ និងដាក់ពាក្យសុំជាថ្មី ដែលក្រសួងមហាផ្ទៃមានរយៈពេលយ៉ាងយូរ ១៥ថ្ងៃទៀត ដើម្បីសម្រេចជាចុងក្រោយលើសំណុំបែបបទនោះ។ ក្នុងមាត្រា១៨ បើសិនជាសំណុំបែបបទមិនទាន់សមស្រប អ្នកដាក់ពាក្យសុំមានរយៈពេល ៤៥ថ្ងៃ នៃថ្ងៃធ្វើការងារ ដើម្បីដាក់សំណុំបែបបទឡើងវិញ (ខណៈនេះដែរ មាត្រា ៣២ នៃច្បាប់អនុញ្ញាតិឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ មានរយៈពេលយ៉ាងយូរ ៤៥ថ្ងៃ ដើម្បីសម្រេចលើសំណុំបែបបទរបស់អង្គការមិនមែនរដ្ឋាភិបាលបរទេស សម្រាប់ការចុះ អនុស្សរណៈ ជាមួយរដ្ឋាភិបាល ដើម្បីប្រតិបត្តិការងារក្នុងប្រទេសកម្ពុជា។)

[១៥] "ល័ក្ខខ័ណ្ឌតម្រូវសម្រាប់ការចុះបញ្ជីជាច្រើន ក្នុងសេចក្តីព្រាងច្បាប់ បង្អាក់ដល់លទ្ធភាពនៃសមាគម ឬអង្គការមិនមែន រដ្ឋាភិបាល ក្នុងការសម្រេចបានឋានៈជានីតិបុគ្គល តាមរយៈដំណើរការប្រកបដោយតម្លាភាព" ការកត់សំគាល់របស់ មជ្ឈមណ្ឌលអន្តរជាតិសម្រាប់ច្បាប់មិនរកផលចំណេញ នៅក្នុងយោបល់របស់ខ្លួនលើសចក្តីព្រាងច្បាប់ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាលរបស់ព្រះរាជាណាចក្រកម្ពុជា ទំព័រ៥។

[១៦] មាត្រា ១៤ និងមាត្រា ១៥

[១៧] មាត្រា ១០ ចែងថា លក្ខន្តិកៈត្រូវតែមាន៖ ឈ្មោះ និងសញ្ញាសំគាល់របស់អង្គការ, គោលបំណង និងទិសដៅ វិធាននៃ ការជ្រើសរើស ការបញ្ឈប់ការបណ្តេញចេញ ការផ្លាស់ប្តូរ ការដកហូតតំណែងសមាជិក បុគ្គលិក ប្រធាន និងថ្នាក់ដឹកនាំ, សិទ្ធិ និងភារកិច្ចរបស់សមាជិក ឬបុគ្គលិក រចនាសម្ព័ន្ធ អាណត្តិតួនាទី ភារកិច្ច ការរៀបចំ និង ការប្រព្រឹត្តទៅនៃអង្គការដឹកនាំនានា, អង្គការដឹកនាំនានា រួមមានសន្និបាត ក្រុមប្រឹក្សាភិបាល គណកម្មាធិការ នាយកគណកម្មាធិការប្រតិបត្តិ និងអង្គការសមមូល, វិធាននៃការប្រជុំសាមញ្ញ និងវិសាមញ្ញនៃអង្គការដឹកនាំនានា, ប្រភពធនធាន និងទ្រព្យសម្បត្តិ, វិធាននៃការគ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិ, វិធាននៃការប្តូរឈ្មោះ ការប្តូរសញ្ញា សំគាល់ និងការធ្វើវិសោធនកម្មលក្ខន្តិកៈ និងវិធាននៃការរំលាយ និងការចាត់ចែងធនធាន និងទ្រព្យសម្បត្តិ នៅពេលបាន រំលាយខ្លួន។

[១៨] ដូច្នេះ មេឃុំ ឬអភិបាលស្រុក អាចរារាំង ឬពន្យាពេលដល់ការចុះបញ្ជីនៃអង្គការ ដោយការជំទាស់មិនផ្តល់នូវលិខិត បញ្ជាក់ប្រភេទនោះ។ (វាគាប់ជួនដែលមិនមានការតម្រូវឲ្យមានការបញ្ជាក់ទទួលស្គាល់ដូច្នេះទេចំពោះអាស័យដ្ឋាន ការិយាល័យក្រុមហ៊ុនឯកជន ដែលចុះបញ្ជីក្នុងប្រទេសកម្ពុជាក្រោមច្បាប់ស្តីពីវិធាននិងការចុះបញ្ជីពាណិជ្ជកម្ម។)

[១៩] មាត្រា ២០ ដល់ មាត្រា ២៤ គ្របដណ្តប់លើការចុះបញ្ជីសម្ព័ន្ធអង្គការ និងមាត្រា ២៧ តម្រូវឲ្យមានការជូនដំណឹងដល់ ក្រសួងមហាផ្ទៃអំពី "កិច្ចសហការ" រវាងអង្គការក្រៅរដ្ឋាភិបាល ឬសមាគម។

[២០] ហេតុផលមួយនៃហេតុផលនានាដែល សាមីអង្គការក្រៅរដ្ឋាភិបាល ឬសមាគម ចូលរួមគ្នាជាសម្ព័ន្ធ គឺដើម្បីធ្វើអោយ ពួកគេមានការការពារច្រើនថែមទៀត និងដើម្បីកាត់បន្ថយនូវលទ្ធភាពដែលរដ្ឋាភិបាលលើកយកតែអង្គការណាមួយ មកចោទប្រកាន់បកវិញ នៅពេលដែលពួកគេធ្វើការស្រាវជ្រាវ ឬបញ្ចេញយោបល់ជាសាធារណៈលើបញ្ហា ចំរូងចំរាសទាំងឡាយ។ នេះអាចពន្យល់បានអំពីចំណាប់អារម្មណ៍របស់រដ្ឋាភិបាលក្នុងការឃ្លាំមើលសម្ព័ន្ធ និងកិច្ចសហការដទៃទៀត រវាងអង្គការក្រៅរដ្ឋាភិបាល ឬសមាគម។

[២១] មាត្រា ៥៥ និង មាត្រា៥៦។

[២២] សេចក្តីសម្រេចលើការចុះបញ្ជី គ្របដណ្តប់ដោយមាត្រា ១៦ ដល់មាត្រា ១៩ (ចំពោះក្រសួងមហាផ្ទៃ) និង មាត្រា ៣១ ដល់ មាត្រា ៣២ (ចំពោះក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ)។ ក្រសួងទាំងនេះអាចផ្អាកសកម្មភាព អង្គការក្នុងស្រុក និងអង្គការបរទេសដែលបានចុះបញ្ជី បើសិនជាពួកគេខកខានពីរដង ក្នុងការដាក់របាយការណ៍ ប្រចាំឆ្នាំជូនរដ្ឋាភិបាល (មាត្រា ៥៣)។ សកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកអាចត្រូវបានផ្អាកក្នុងរយៈពេលពី មួយ ទៅបីខែ ខណៈដែលអង្គការក្រៅរដ្ឋាភិបាលបរទេសអាចត្រូវបញ្ជាឲ្យផ្អាកសកម្មភាពរបស់ពួកគេ (ក្នុងរយៈពេលដែលមិនមានចែងកំណត់ក្នុងច្បាប់) ឬក៏ "បញ្ចប់សុពលភាព" នៃអនុស្សរណៈរបស់ពួកគេជាមួយរាជរដ្ឋាភិបាល។

[២៣] ក្នុងប្រទេសដែលពោរពេញទៅដោយអំពើពុករលួយ ដូចជាប្រទេសកម្ពុជា គ្រោះថ្នាក់ដែលមន្ត្រី អាចស្វែងរកប្រាក់ សំណូកពីអ្នកដាក់សំណុំបែបបទ គឺមានកំរិតខ្ពស់ ដែលបង្កើតនូវឧបសគ្គបន្ថែមទៀតចំពោះការចុះបញ្ជី។ សូម្បីតែ គ្មានការទាមទារយកប្រាក់សំណូក ក៏នៅមានលទ្ធភាពនៃតម្លៃខ្ពស់ហួសហេតុ នៃតម្លៃផ្លូវការសម្រាប់ការចុះបញ្ជី ដែលនឹងជាការរារាំងផងដែរដល់ អ្នកដាក់សំណុំបែបបទ។ (ច្បាប់កំណត់ឲ្យមានការបង់ថ្លៃចុះបញ្ជី ចំពោះសមាគមអង្គការមិនមែនរដ្ឋាភិបាល និងសម្ព័ន្ធអង្គការ សមាគមក្នុងស្រុក ប៉ុន្តែមិនបញ្ជាក់ពីចំនួនទឹកប្រាក់ ឬក៏កំណត់ថាវាគួរតែ គ្របដណ្តប់តែលើ ចំណាយរដ្ឋបាលស្របច្បាប់ទេ។)

[២៤] ១៧ ចែងថា ក្រសួងមហាផ្ទៃត្រូវពិនិត្យ នីត្យានុកូលភាពនៃលក្ខន្តិកៈរបស់អង្គការ ហើយមាត្រា ១៨ ចែងថា ក្រសួងមហាផ្ទៃ អាចកំណត់ ថាតើសំណុំបែបបទសុំចុះបញ្ជីមានខ្លឹមសារស្របតាមរដ្ឋធម្មនុញ្ញ ឬច្បាប់នានាជា ធរមាន។

[២៥] មាត្រា ៤៩ មាត្រា ៥០ និង មាត្រា ៥២។

[២៦] ដូចដែលមជ្ឈមណ្ឌលអន្តរជាតិសំរាប់ច្បាប់មិនរកផលចំណេញ បានកត់សំគាល់ ក្នុងយោបល់របស់ខ្លួន លើសេចក្តី ព្រាងច្បាប់ (ទំព័រ ៨) ថា "សេចក្តីព្រាងច្បាប់ផ្តល់នូវបទដ្ឋានមិនគ្រប់គ្រាន់ ដើម្បីដឹកនាំដល់ការធ្វើសេចក្តីសម្រេចចិត្ត របស់រដ្ឋាភិបាលលើការផ្អាក ឬបញ្ចប់សកម្មភាពអង្គការ។ សេចក្តីព្រាងច្បាប់មិនបង្ហាញពី ការដាក់ដែនកំណត់ ដល់ការប្រើប្រាស់ ការបញ្ចប់សកម្មភាព ថាជាទណ្ឌកម្មជម្រើសចុងក្រោយនោះទេ។ មិនមានការតម្រូវ ចំពោះអាជ្ញាធររាជរដ្ឋាភិបាលឲ្យផ្តល់ការជូនដំណឹង និងឱកាសដើម្បីធ្វើការកែតម្រូវបញ្ហា មុនការសម្រេចផ្អាក ឬបញ្ចប់សកម្មភាព និងមិនមានការនិយាយពីសិទ្ធិប្តឹងតវ៉ាក្រោយពីការសម្រេចផ្អាក ឬបញ្ចប់សកម្មភាពទេ។ មើលជារួមលើចំនុចនេះ គឺថានិតិវិធីនៃការផ្អាក និង/ឬការបញ្ចប់ គឺបើកផ្លូវឲ្យរដ្ឋាភិបាលប្រើល្បិចបំភាន់ និងអាចប្រើមធ្យោបាយលើស ពីនេះទៀត។

[២៧] មាត្រា ៥៤។

[២៨] មាត្រា ៤៦ មាត្រា ៤៨ និង មាត្រា៥៤។

[២៩] មាត្រា ៤៣

[៣០] មាត្រា ៣០ មាត្រា ៣៣ មាត្រា ៣៦ និងមាត្រា ៣៧។

[៣១] មជ្ឈមណ្ឌលអន្តរជាតិសំរាប់ច្បាប់មិនរកផលចំណេញ យោបល់លើសេចក្តីព្រាងច្បាប់ ស្តីពី សមាគម និងអង្គការមិនមែនរដ្ឋាភិបាល របស់ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២២ ខែធ្នូ ឆ្នាំ២០១០ ទំព័រ១០។

[៣២] របាយការណ៍តំណាងពិសេសអគ្គលេខាធិការអង្គការសហប្រជាជាតិខាងអ្នកការពារសិទ្ធិមនុស្ស ហ៊ីណា ជីឡានី ថ្ងៃទី១ ខែតុលា ឆ្នាំ២០០៤ A/59/401 ទំព័រ២។ សម្រាប់ការពិភាក្សាលើបទពិសោធន៍នៅបរទេសជាមួយនឹង ច្បាប់អង្គការក្រៅរដ្ឋាភិបាល សូមមើលផងដែរ ឯកសារសង្ខេបអង្គការលីកាដូ ច្បាប់អង្គការមិនមែនរដ្ឋាភិបាល និងការបង្ក្រាប លើអ្នកការពារសិទ្ធិមនុស្ស៖ មេរៀនអន្តរជាតិសម្រាប់ប្រទេសកម្ពុជា ខែវិច្ឆិកា ឆ្នាំ២០០៨។